# មជ្ឈមណ្ឌលឯកសារកម្ពុជា
# ឆាយ ជួន

*សម្ភាសជាមួយ **ឆាយ ជួន** ភេទប្រុស អាយុ ៦៥ឆ្នាំ*

*នៅភូមិត្រពាំងគូ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ*

*នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៥*

*សម្ភាសដោយៈ ស៊ិរ សាវីណា និង សាន់ កល្យាណ*

ជួនៈ ឪពុកខ្ញុំបាទដែលគេសម្លាប់និងឈ្មោះ ឆាយ រ៉ិត ហើយខ្ញុំឈ្មោះ ឆាយ ជួន ត្រូវជាកូនតារ៉ិតនិងណា

សាវីណាៈ លោកតាឥឡូវអាយុប៉ុន្មានហើយ?

ជួនៈ អាយុ ៦៥

សាវីណាៈ លោកតាស្រុកកំណើតនៅឯណាដែរ?

ជួនៈ ស្រុកកំណើតនៅត្រពាំងគូរនិងម៉ង

សាវីណាៈ ឥឡូវក៏គេនៅហៅអញ្ចឹងដែរហេះលោកតា?

ជួនៈ បាទ នៅហៅអញ្ចឹងដែរ ហើយខ្ញុំសុំជំរាបអ្នកគ្រូថា ភូមិត្រពាំងគូរយើងនេះណា បើអ្នកគ្រូមិនជឿខ្ញុំចូលសួរស្នាក់ការនេះដឹងហើយ ភូមិគំរូអញ្ចឹងតែម្តង គេថាឃុំគំរូ តាំងពីអណ្តូងទឹកក៏ស្អាត ស្រែក៏ស្អាត ស្រែល្អលើសគេ ហើយជីវភាពអីចាន់ សារុនគាត់មកសរសើរហើយ សូ ឃុន និងគាត់ចូលមក ដូវថ្នល់ខ្ញុំបាទ បានលើកខ្វាត់ខ្វែងឲ្យឡានចូលរួចហើយណាអ្នកគ្រូ បាទខ្ញុំព្រមទាំងមេភូមិ គណៈកម្មការ ខ្ញុំនិងអាចារ្យវត្តបំផុសលើកថ្នល់ពីព្រៃជាតិទៅទល់វត្តបូរ ពីថ្នល់ជាតិបុកមកអញ្ចឹងទៅ ទៅទល់ត្រពាំងត្រាច អញ្ចឹងខ្វាត់ខ្វែងរហូតពេញទឹកពេញដី ជួយបណ្តុះបណ្តាលខាងនេះនិង ហើយអញ្ចឹងគាត់មកជួបប្រជាពលរដ្ឋនិងឃើញខ្វះខាតអីគាត់ជួយបំពេញនិងណា នរណាខ្វះមាន់ គាត់ទិញ មាន់គាត់ទិញមាន់ឲ្យ នរណាខ្វះ ខ្វះទីទាល់ ដូចខ្ញុំអីជាដើម គាត់លើកដែរ គាត់ថា ត្រពាំងគូរនេះមិនសូវមានអ្នកទីទាល់អីប៉ុន្មានទេ ១០ វាមានមួយអីអញ្ចឹងទៅណាអ្នកគ្រូ។

សាវីណាៈ លោកតារៀបការពីអង្កាលដែរលោកតា?

ជួនៈ ខ្ញុំភ្លេចហើយអ្នកគ្រូ ខ្ទង់៦០ជាងនិង

សាវីណាៈ តាំងពីលោកតាអាយុប៉ុន្មាន?

ជួនៈ ខ្ញុំបួសតាំងពីឆ្នាំពីឆ្នាំ ១៩៦៣ ហើយខ្ញុំមកការនិងខ្ញុំ១៩៦៤-៦៥និង ខ្ញុំបានរៀប ការនិងណា

សាវីណាៈ គ្រួសារលោកតាឈ្មោះអីលោកតា?

ជួនៈ ឈ្មោះ ខៀវ យ៉ាន់

សាវីណាៈ យាយព្រះជន់ប៉ុន្មានហើយឥឡូវ?

ជួនៈ ៦៤ ខ្ញុំ៦៥

កល្យានៈ អញ្ចឹងពីក្មេងលោកតាបានបួសផង?

ជួនៈ បាទ បានបួស

កល្យានៈ បួសអាយុប៉ុន្មានលោកតា?

ជួនៈ ខ្ញុំបួសបំពេញភឹកតែម្តងអាយុ២០

កល្យានៈ ហើយបានប៉ុន្មានសឹក?

ជួនៈ បានជិត២ឆ្នាំ ឪពុកខ្ញុំគាត់ធ្វើអាចារ្យវត្ត ហើយពីដើមអ្នកគ្រូខ្ញុំសុំជីរាប ស្រែគាត់ច្រើន ណាស់ ហើយអញ្ចឹងកូនអើយ មិនបាច់នៅធ្វើគ្រូអីគេទេ កូនតែមួយ ស្រូវយើងហូប អត់ខ្វះ គោជីកមិនអស់ អញ្ចឹងកូនឯងទៅបួសតបស្នងឪពុកម្តាយបានប៉ុណ្ណឹងបានហើយ អស់ជាងមួយវស្សាណា៎

សាវីណាៈ អញ្ចឹងបានន័យថាលោកតាមានតែឯងទេ អត់មានបងប្អូនទេ?

ជួនៈ ខ្ញុំមានប្អូនស្រី៤នាក់ ប្រុសតែខ្ញុំមួយទៅ

សាវីណាៈ ប្អូនៗលោកតានៅទាំងអស់ឬមួយ...?

ជួនៈ ប្អូនខ្ញុំស្លាប់២នៅ៣ទាំងខ្ញុំនិងហេះ នៅពោមួយ បន្ទាប់ពោមួយ និងខ្ញុំនិងតែម្តង ហើយ គ្រាន់បើដែរណា មិនទីទាល់ទេអ្នកគ្រូ មានហូបបរិបូរ មិនខ្វះខាតរឿងហូបចុកទេណាអ្នក គ្រូ តែលុយកាក់អីវាខ្វះខាតអញ្ចឹងដែរ តែបាយមានហូបគ្រប់គ្នាអញ្ចឹង ប្អូនខ្ញុំនៅជុំវិញ និង អត់មាននៅឆ្ងាយទេ ហើយសំឡឹងមើលចុះឃើញដូចថាគ្រាន់នៅគ្រប់គ្នាអញ្ចឹងទៅ ណាអ្នកគ្រូ តែគ្រាន់តែខ្វះលុយចាយតែមួយមុខទៅណាអ្នកគ្រូ បើថាបាយហូបមាន ។ ហើយបើស្រែវដ្តដូចគ្នា ២០អា ស្មើរគ្នាទាំងអស់

សាវីណាៈ ប្អូនលោកតាស្លាប់ពីជំនាន់ណាដែរ?

ជួនៈ ស្លាប់ឥឡូវនិងទេ មិនមែនជំនាន់ប៉ុលពតទេ ប៉ុលពតស្លាប់តែឪពុកខ្ញុំទេ គេសម្លាប់ទេ ណា

សាវីណាៈ ឪពុកលោកតាឈ្មោះអី?

ជួនៈ ឆាយ រ៉ិត

សាវីណាៈ ចុះម្តាយ?

ជួនៈ ម្តាយឈ្មោះ សុខ សែម

សាវីណាៈ ស្រុកកំណើតគាត់នៅឯណា?

ជួនៈ ស្រុកកំណើតគាត់នៅត្រពាំងគូរទាំងអស់ ទាំងយាយទាំងតា អញ្ជឹងខ្ញុំសូមជំរាបអ្នកគ្រូម្តងទៀត ក្នុងពេលបោះឆ្នោតម្តងៗក្នុងឃុំត្រពាំងគូរទាំងមូល មានតែតាឆាយទេនាមត្រកូលបើអញ្ជឹងប្រជាពលរដ្ឋក្នុងត្រពាំងគូនិងជាង១០០នាក់និងសុទ្ធតែឆាយទាំងអស់ នាមត្រកូលចេញមកឆាយទាំងអស់ ខ្ញុំជំរាបអញ្ជឹងម៉ង

កល្យានៈ ម៉ិចអញ្ជឹង?

ជួនៈ អញ្ជឹងបានតាអានគាត់សួរនិងណា យីចុះត្រពាំងគូរទាំងគូរទាំងមូលនិងនេះក៏ឆាយ នោះក៏ឆាយទាំងអស់គ្នា ព្រោះថាត្រកូលនិងវាមូលដូចជីដូនមួយអញ្ជឹងទៅ ចេះតែបែកគ្នាយកនិងទៅ វាចំត្រកូលអញ្ជឹងទៅអ្នកគ្រូ អត់មានទៅឆ្ងាយទេ អត់មានពីណាមកនិយាយអីទេ ចាស់ទុំគាត់រៀបចំបានតែក្នុងពូជ ក្នុងអំបូរនិងទៅណា អញ្ជឹងមានតែតាឆាយជួន ឆាយសៅ ឆាយសុខអីអញ្ជឹងទៅណ៎ ដល់អញ្ជឹងចូលមណ្ឌលនីមួយៗមានតាឆាយទាំងអស់ បានគាត់ស្គាល់និងណា អ្នកបោះឆ្នោតនិងស្គាល់អញ្ជឹងណា

កល្យានៈ លោកតារៀបរាប់ប្អូនខ្ញុំលោកតាតិចមើល?

ជួនៈ ប្អូនខ្ញុំឈ្មោះទីមួយខ្ញុំបាទឈ្មោះ ឆាយ ជួន បន្ទាប់មកស្រីឈ្មោះ ឆាយសំ បន្ទាប់មកទៀតប្អូនស្រីដែរឈ្មោះ ឆាយស៊ីង បន្ទាប់មកទៀតឈ្មោះ ឆាយប៉ិច រស់នៅសព្វថ្ងៃ បន្ទាប់ មកទៀតឈ្មោះ ឆាយសារិន រស់សព្វថ្ងៃដែរ គ្រប់៥នាក់តែម្តង។ ឆាយសំ និងឆាយស៊ីននិងស្លាប់ហើយ ។

កល្យានៈ លោកតាកើតឆ្នាំអី?

ជួនៈ ខ្ញុំភ្លេចឆ្នាំហើយអ្នកគ្រូអើយទាល់តែយក......

កល្យានៈ អត់ទេ ឆ្នាំសត្វណា៎

ជួនៈ ខ្ញុំឆ្នាំម្សាញ់ បើសួរអញ្ជឹងបានដឹង

កល្យានៈ លោកតាមានប្រសាសន៍ម្តងទៀតមើល កាលពីគេសម្លាប់ឪពុកលោកតានិងពេលណាហើយយ៉ាងម៉ិចទៅកាលនិង?

ជួនៈ កាលគេសម្លាប់ឪពុកខ្ញុំគេសម្លាប់ម៉ោង៨ថ្ងៃល្ងាច ឪពុកខ្ញុំទាំងអស់ កូនទាំង៥នាក់និងកាលនិងណ៎ នៅទាំង៥មកយកអង្ករ

កល្យានៈ អញ្ជឹងកូនកាលនិងនៅបែកគ្នា អត់នៅជុំឪពុកទេ?

ជួនៈ កូនគាត់នៅក្នុងបន្ទុកគាត់៤នាក់ ហើយខ្ញុំការហើយមកនៅនេះ អញ្ចឹងដល់ពេលនៅជិត គ្នា ខ្ញុំនៅភូមិជិតនេះ នៅភូមិចេតីយនិង ដល់តែពេលហៅមកយកអង្ករ ផ្ទះវាធំណាអ្នក គ្រូ ពីដើមមិនមែនផ្ទះតូចទេ ផ្ទះធំណាស់ អញ្ចឹងឡើងទៅយកគេរត់ចុះមកគ្នា៣នាក់ ខ្ញុំ ហើយនិងប្អូនៗនិងរត់រួចទាំងអស់ ហើយគេដេញបាញ់នោះណា បាញ់អញ្ចឹងទៅឪពុកខ្ញុំ ចុះមកក្រោយគេ គេចាប់ជាប់ ខ្ញុំស្មានតែគេយកទៅលិច ដឹងអីគេបាញ់ចោលនៅនិង ៣ គ្រាប់អ្នកគ្រូ ចំករ២គ្រាប់ ត្រង់នេះមួយគ្រាប់ ត្រង់នេះមួយគ្រាប់ នេះមួយដែរ ហេះ

កល្យានៈ អូ!

ជួនៈ ហើយដៃគាត់ គាត់ស្លៀកគាត់ខោអាវដៃត្រឹមនេះ ហើយកន្សែងសរពាទា ហើយក្នុងនេះ ខ្សែគោ គាត់ព្រលែងគោផង គោ៩លែងចោលទាំងអស់ អញ្ចឹងឲ្យខ្ញុំដឹងតែអាឈ្មោលៗ ទៅទេ មេលែងចោលទាំងអស់ ដែលស្លាប់និងគាត់បត់ជើងសំពះគេអញ្ចឹងហេះ ដៃអត់ លៀទេអ្នកគ្រូ នៅអញ្ចឹងហេះ

កល្យានៈ អូ!

ជួនៈ ហើយស្លាប់អញ្ចឹងហេះអ្នកគ្រូ បត់ជើង ដល់ពេលដាច់ខ្យល់ទៅ ជើងម្ខាងគ្រាន់តែលៀ តិចប៉ុណ្ណេះទេណា៎ អាក្រោមនេះនៅបត់ទេអញ្ចឹងហេះ ហើយអាពោះនេះវាដឹតភ្លៅនេះ អញ្ចឹងដីខ្សាច់ភ្លូកកន្ទែងនិងណាអ្នកគ្រូ អញ្ចឹងដីខ្សាច់និងវាបឺតអស់ បឺតអាខ្ទុះវាហូរពីនិង មកនិងណា គ្រប់១២ថ្ងៃ ហើយថ្ងៃក្ដៅខែផល្គុណចែត្រ អ្នកគ្រូដឹងហើយ ខ្ញុំមកក្រៀម ដូចកន្ទែបយើងអញ្ចឹង អត់មានធុំក្លិនស្អុយទេ ស្អាបតែម្ដង

កល្យានៈ អញ្ចឹងលោកតារត់១២ថ្ងៃទើបហ៊ានបកមកវិញ?

ជួនៈ បាទ យី! វាបិតអង្គតាសោម ដាច់ផ្លូវនិងហេះ អត់មានរណាចូលបានទេ គេឃ្លឹបជាប់ ដែរនិង

កល្យានៈ កាលនិងខែប៉ុន្មានលោកតា?

ជួនៈ ឆ្នាំ៧១

កល្យានៈ ខែប៉ុន្មាន? ដើមឆ្នាំ ឬចុងឆ្នាំ?

ជួនៈ ដើមឆ្នាំអ្នកគ្រូ ខ្ទង់ខែពិសាខ ខែជេសនិង ស្មៅដុះហើយនិង ហើយខ្ញុំរត់ទៅដល់តាកែវ និង ខ្ញុំជួបបងប្អូនគាត់និងណា ថាឥឡូវគេបើកបានហើយក្មួយឯងទៅមើលឪពុកមើល គេចាប់យកទៅលិចឬមួយយ៉ាងម៉ិចៗ ដល់អាប្អូនៗនិង វារត់ទៅលិច ដល់គេឡើងវិ ដល់អង្គតាសោមនេះ មានទាហានម្នាក់ សាដង់សែប ខ្ញុំអាណិតតាមួយដល់ហើយ មាឌ ដូចពូឯងអញ្ចឹង ស្លាប់នៅភូមិជើងនេះ ពាក់អាវសស្លៀកខោឡាញ់ ខ្ញុំអារម្មណ៍ហើយ ខ្ញុំ

ថាអញ្ចឹងឪខ្ញុំហើយ មើលទៅញោមខ្ញុំហើយយ៉ាង ដល់តែមកមែន ឡើងក្រៀមហើយ អ្នកគ្រូ ក្រៀមកំប៉ិត ៗ អញ្ចឹងខ្ញុំក៏ត្រលប់មកវិញមកយប់និង ដល់តែឃើញខ្ទង់ថ្ងៃថ្មើរនិងហេះ អញ្ចឹងខ្ញុំអត់បានយកគាត់ទេអ្នកគ្រូ គ្រាន់តែយកខ្សែគោស្រាយពីនិងមកទាក់ពីដើមវាគ្មានខ្សែនីឡុង សុទ្ធតែខ្សែធាងត្នោត ជក់ត្នោតនិងណា៎ ទាក់និងពូខ្ញុំមួយគាត់ថាក្អួយឯងទាក់ចង្កេះគាត់ទៅហើយទាញទៅ ក្រែងលោកគេកប់គ្រាប់បែកណា៎ ដឹងទេខ្លាចគេដាក់គ្រាប់បែកទៀតណា ដល់អញ្ចឹងខ្ញុំទាក់ទៅ តខ្សែគោប្រហែលជា១០កន្ទុយឆ្ងាយណាស់អ្នកគ្រូ ហើយទាញដើមដូងទៀតណា ហើយទាញផ្ងារមកអញ្ចឹងហើយមានអី រីកក្រញ៉ាំងអញ្ចឹងនិង ដូចកង្កែបក្រៀមអញ្ចឹង ហើយនិយាយពីមាន់ក្នុងភូមិកូនចៅផង បងប្អូនគាត់ផង ផ្ទះ៤ មាន់ប្រហែលជា៥០-៦០ សុទ្ធតែមេ ហើយទាពងពេញសរសំពោងពេញត្រពាំង ប្រហែលជា៥០-៦០ទាណា៎ សរសំពោង ចុះ១២ថ្ងៃហើយ អញ្ចឹងវាកាយស៊ីដង្កូវដែលចេញមកពីពោះនិង ស៊ីរលីង មាន់កកាយស៊ីនិង កាយស៊ីអស់រលីង ដីខ្សាច់និង កាយខូងអស់រលីង ហើយគោ១២ថ្ងៃនិងវាមានទៅណាវា វាមកដេកនៅជុំវិញនិង ម៉ដដី អាចម៍នៅនិង ជុំវិញនិង ហើយដល់ពេលទាហានឡើងបើកដល់អន្លុតាសោម កាំភ្លើងវាឌុងឌាំង ទាហាននិងមិនដឹងជាវារត់ទៅណាអស់ទៅ ខ្ញុំរកអត់ ឃើញ ហើយដល់ពេលខ្ញុំនិមន្តលោកវត្តសិង្ហមកបូជាគាត់ហើយ ខ្ញុំយកធាតុគាត់មកដាក់ នេះខ្ញុំសុំតែឆ្អឹង ដឹងត្រង់ណាទេ ឆ្អឹងនិងប៉ុននិង ហើយប្រវែងនិងហេះ ខ្ញុំដាក់ទៅ ខ្ញុំដុតធូបហើយខ្ញុំថ្វាយបង្គំគាត់ទៅ ខ្ញុំថាកូនអត់មានរត់ទៅណាទេ កូនសុំលោកឪពុកតស៊ូ ចាប់ពីថ្ងៃនេះ សងឈាមលោកឪពុក ថាអញ្ចឹងណា ដល់ទៅតស៊ូលន់ណុល កាលនិងមានចៅហ្វាយខេត្តពាន ទ្រី គាត់នៅធ្វើចៅហ្វាយខេត្តទៅសុំគាត់ធ្វើទាហាននិងណា គាត់ឲ្យធ្វើគាត់ថ្លឹងកំពស់អីណា ត្រឹមត្រូវអីហើយ គាត់ឲ្យចូលធ្វើ ដល់ហើយខ្ញុំទៅតស៊ូនិង បានឆ្អឹងទៅ ឲ្យយាយខ្ញុំនិង កាលនិងខ្ញុំមានកូនតែមីបងមួយទេណា៎ អញ្ចឹងដេរហើយធ្វើដូចការថាអញ្ចឹងណាអ្នកគ្រូ ធ្វើខ្សែកហើយដាក់ឆ្អឹងនៅក្នុងនិងនិងណា ហើយដុតធូបទៅពេលគេបញ្ជូនទៅឡើងវ៉ៃនេះណា ជិតទៅថា លោកឪពុកជួយការពារកូនផង កូនសុំសងឈាមជូនលោកឪពុកហើយ ដល់ហើយអ្នកគ្រូអើយឡើងទៅ៥ឆ្នាំអត់មានអីទេអ្នកគ្រូ អត់មានគ្រាប់អីជិតទេ ហើយគេសាប់សែងពេញវាល ខ្ញុំអត់មានអី តែខ្ញុំអត់ដែលឡើងទៅវ៉ៃខេត្តគេដទៃទេណា វ៉ៃតែតាកែវអន្លុតាសោមទេណា វ៉ៃបើកផ្លូវណា អត់ ហើយដំណមខ្ញុំតាំងពីឪខ្ញុំរហូតមកគ្រូខ្ញុំមកគាត់ថា ទីមួយតមប្រពន្ធគេណា ដាច់ខាតហើយ កូនក្រមុំគេ ជេម្រាយគេ មើលងាយសត្រូវ កុំឃើញគេដើរហើយនិយាយថា ហ៊ឺសអញ

បាញ់ហ្វែនឥឡូវហើយអាចោម្រាយអីអញ្ចឹងកុំថាណា ចុះបើគេធ្វើយើងយើងធ្វើវិញទៅ យើងកុំមានប៉ងដាក់គេ និងដំណមគ្រូខ្ញុំណា ហើយគាត់ថាបើចូលទៅភូមិគេអញ្ចឹងបើ ឃើញមានដូង ត្របែកអី ម្ចាស់គេមិនទៅមែនពិត ផ្ទះគេឆេះអស់មែនពិត តែមានប្រ ភូមិ ម្ចាស់ស្រុកអីគេនៅថែទាំគេនិងណា អញ្ចឹងឃើញដូងឃើញអីគេ សុំគេទៅ សុំ មួយបេះមួយ សុំពីរបេះពីរ គ្រូខ្ញុំគាត់ផ្តាំតែប៉ុណ្ណឹងទេ អញ្ចឹងខ្ញុំឡើងទៅព្រៃផ្អេ។ និ យាយពីដូងអ្នកគ្រូអើយ ដើមទាបៗ ផ្លែនោះមហាផ្លែ ខ្ញុំមានបាយយាយគាត់ដាំបាយ ឲ្យទៅដាក់ការម៉ែលមួយទៅ ដាក់សាក់ការដូទៅ ស្ពាយទៅ ស្រេកទឹកដូងពេក ម្ចាស់ទឹក ម្ចាស់ដីអើយសុំដូងមួយ សុំមួយបេះមួយតែម្តង ហូបហើយគេមកវិញ និយាយពីចូល វត្តខ្នាខាងត្បូងហេះ គេវែកដូងទុំមានម្នាក់៥០-៦០ផ្លែ អាដូងវាជ្រុះណា យាយខ្ញុំគាត់ ថា ចុះឪមីងវ៉ើតឯងគេវែកដូងគ្រប់គ្នាម៉ិចក៏មិនវែក ខ្ញុំថាហ៊ឹស យាយឯងថានិងចេះតែ ថាបានហើយ ជីវិតគ្មាននរណាដាក់លក់តាមផ្សារទេ ខ្ញុំថាអញ្ចឹង ហើយខ្ញុំអត់ដែលមាន អីទេ ហើយបើខ្ញុំបានឃើញសត្រូវ ខ្ញុំឃើញឆ្ងាយ ប្រហែលជាប្រវែងនិងទៅផ្ទះគេដើង នោះ អីមិនដែលឃើញ ហើយបើខ្ញុំឡើងទៅនៅចាំ ឡើងមកយើងមកដាក់ស្នាក់ការនៅ ឯណា ឧទាហរណ៍ថាតាមថ្នល់អីអញ្ចឹងមានផ្ទះគេអញ្ចឹងទៅ ដាក់ស្នាក់ការផ្ទះគេដែលមិន ឆេះនិងណាអ្នកគ្រូ អញ្ចឹងដាក់ស្នាក់ការនៅកន្លែងនិងទៅ យប់ឡើងដេកគេមកឆ្នក់បាញ់ អញ្ចឹងដែរណា៎ ដល់ពេលព្រឹកឡើង ឡើងចេញអាវ៉ង់សោះនិងណា អញ្ចឹងវាបាញ់ដែរ ខ្ញុំដែលកុនដែរដីប្រហែលជា១០ម៉ែត្រវាចោលគ្រាប់បែកអត់ដល់ ដល់ខ្ញុំចូលគំនូសដី ហើយអ្នកដើរជាមួយខ្ញុំនិងស្លាប់គេបាញ់ត្រូវ បាញ់ត្រូវកំប៉េះគូថនេះ លឺសូរឡើងផ្លប់ ចាក់ទឹកក្នុងគន្ធក់អាបេ ហើយវាចោលគ្រាប់បែកមកជិតដល់ដែរនិងផ្ទះ ហើយខ្ញុំបាញ់ ប្រហែលជាអស់៣-៤បង់ដែរទៅ វាឡើងរត់ទៅៗ រត់ទៅអាសង់សែងជ្រុំផាប់ដែរនិង មិនថាមិនផាប់ទេ

កល្យានៈ កាលពីលោកតាចូលធ្វើទាហាននិង ប្រពន្ធលោកតានៅឯណា អាយុប៉ុន្មានលោកតា?

ជួនៈ អាយុ៤៥

កល្យានៈ ឆ្នាំ១៩៧១និងហេះ?

ជួនៈ បាទ

កល្យានៈ ប៉ុន្មានខែបន្ទាប់ពីឪពុកខូចទៅ?

ជួនៈ គ្រាន់តែឪពុកស្លាប់ភ្លាម ខ្ញុំទៅភ្លាមនិង ទៅចូលធ្វើទាហានភ្លាម បូជាហើយ យកធាតុ គាត់មកដាក់ចេតីយ៍នេះខ្ញុំមកវិញ ចូលថ្ងៃនិងតែម្តងនិង សុំគេធ្វើ

កល្យាន: ចុះពេលលោកតាទៅ ប្រពន្ធលោកតានៅនិងភូមិនិងដដែល?

ជួនៈ អត់ទេ ទៅនៅតាកែវជាមួយគ្នាទាំងអស់ នេះគ្មាននរណានៅទេ នៅរួមគ្នាក្នុងទីក្រុងម៉ង និង

កល្យាន: ហើយចុះប្អូនៗ?

ជួនៈ ប្អូនៗគេទៅនៅលិច២ នៅជាមួយខ្ញុំនេះ៣នាក់

កល្យាន: លិចនិងនៅឯណា?

ជួនៈ អាពតគេយកទៅ ភ្នំដីវីរមៀលណោះ

កល្យាន: អូ! គេកៀរបានទៅ?

ជួនៈ បាទ ទៅនៅជាមួយគេភ្នំដីវីរមៀលណោះណា

កល្យាន: គេដេញបាញ់ឪពុកនិង រត់ទៅ រត់ជុំគ្នាដែរអត់ទេ?

ជួនៈ រត់ទៅ ជុំគ្នា រត់ទៅជុំគ្នា ដល់ពេលទៅដល់នោះ វាដូចថា វាញ៉ៅកញ៉ាកទៅ វាបែកគ្នាណា ខ្ញុំនិងបែកដោយឡែកទៅ ប្អូនពីរនាក់គេបែកដោយឡែកហើយ តាមគ្នាតាមក្មេងនិងណា អញ្ចឹងដល់ពេលនេះ មានរទេះមានអី បរទៅលិចទាំងយប់អីនិងទៅណា ហើយដល់ពេលទៅដល់នោះអត់ឃើញឪពុកៗ ដល់អត់ឃើញឪពុកខ្ញុំ ១២ថ្ងៃគេឡើងវៃអន្តតាសោមបាន បានខ្ញុំមកឃើញឪពុកស្លាប់នៅនេះនិង មកឃើញហើយខ្ញុំបូជាហើយ ខ្ញុំប្រាប់គាត់ហើយ ខ្ញុំមកធ្វើទាហានជាប់ទៅ ទាល់តែ៧៥បែកតែម្តង

កល្យាន: បែកនិងគេដឹងថាលោកតាធ្វើទាហានលន់ណុលដែរអត់?

ជួនៈ ហីមិនដឹង មកប្រវត្តិខ្ញុំមាន តែកាលនិងខ្ញុំចេញមកគេឲ្យខ្ញុំធ្វើជាងសំណង់ ហើយប្រវត្តិរូបគេដាក់ទាហាន គេដាក់អញ្ចឹង

កល្យាន: អូ! គេដឹងតែម្តង?

ជួនៈ គេដឹង ចុះវាសុទ្ធតែឈ្លបតាមនិង គេមិនស្គាល់យ៉ាងម៉ិច

កល្យាន: ឈ្លបនិង ឈ្លបអ្នកភូមិនិងហេះ?

ជួនៈ អ្នកភូមិ បងប្អូនដែរនិងណ៎ា សុទ្ធតែបងប្អូនជីដូនមួយ ជីទួតមួយអីនិងណាអ្នកគ្រូ ជិតតើតែខ្ញុំផលបុណ្យនេះនោះវាចេះតែនៅទៅណា គេសួរដែរតើ កាលពីធ្វើទាហាននៅ Batallion ណ៎ា គេសួរអញ្ចឹងទៀត

កល្យាន: អូ! គេធ្លាប់សួរប្រវត្តិរូបដែរ?

ជួនៈ បាទ ខ្ញុំប្រាប់គេតាមត្រង់ ខ្ញុំកុហកគេធ្វើអី ខ្ញុំនៅ Batallion លោកស្នងស័ក្តពីរហើយគាត់ឲ្យធ្វើអីខ្លះថា មានឲ្យធ្វើអី ឡើងវៃអីនិងខ្មែរក្រហមអីអញ្ចឹងដែរ

សាវីណាៈ អត់អីដែរលោកតា?

ជួនៈ អត់អី

កល្យានៈ គេមានប្រុងយកលោកតាទៅណាដែរអត់?

ជួនៈ អត់ដែលសោះ តាំងពីខ្ញុំចូលមកនៅ វាបានមានបងប្អូនខ្ញុំគេធ្វើឈ្លបណា៎

កល្យានៈ អូ! មានបងប្អូនគេជួយការពារដែរហេះ?

ជួនៈ បាទ ជួយការពារ ធ្វើឈ្លប អញ្ចឹងខ្ញុំគ្រាន់តែចូលក្នុងភូមិភ្លាមបែកហើយគេរួមស្រែ រួមទឹក រួមដីទាំងអស់ តាំងពីនេះ ធ្វើការរួមណាអ្នកគ្រូ ដល់ធ្វើការរួម យាយខ្ញុំនិងតាត់កងចល័ត គាត់ទៅស្ទូងទៅដកដេកនៅឆ្ងាយៗណាស់ ហើយម្ដាយខ្ញុំចាស់គេឲ្យគាត់ចាំផ្ទះ ខ្ញុំនៅប្អូនស្រីមួយនិងគេឲ្យធ្វើការនៅភូមិណា៎ ឲ្យធ្វើការធ្វើការនៅភូមិនិង ប្អូនស្រីនិងរែកដីដំបូក ហើយអាកូនប្រុសមួយនោះនៅតូច គេឲ្យរើសអាចម៍គោ

សាវីណាៈ កាលនិងកូនប្រុសលោកតាអាយុប៉ុន្មានហើយ?

ជួនៈ កូនស្រីខ្ញុំ១០ឆ្នាំជាងហើយ ហើយកូនពៅខ្ញុំនិង១១ឆ្នាំ

សាវីណាៈ ចុះលោកតាពេលដែលបែក៧៥ដំបូងនិង គេជម្លៀសលោកតាមកនេះឬមួយលោក មក?

ជួនៈ ខ្ញុំគេជម្លៀសឲ្យទៅនៅវត្តចម្បារ ខាងលិចអន្លុតាសោមណោះ បានប្រហែលជា១ខែទើបអង្គការគេឲ្យមកនៅតាមភូមិ គេមានប្រធានភូមិ ប្រធានក្រុមគេអោបក្ដាប់ហើយ អ្នកគ្រូ អញ្ចឹងមកដល់គេចាត់កម្លាំងឲ្យខ្ញុំនេះធ្វើស្ពានដីកប្រឡាយអីនិង ហើយខ្ញុំធ្វើស្ពានតាមថ្នល់និងរហូតទៅធ្វើនៅកន្ទែងឡខាងលិចតាកែវណោះ ធ្វើស្ពានីយបូមទឹក ដល់តែចប់អានិងទៅគេឲ្យដើរធ្វើចាក់ធ្វើលានបោកស្រូវតាមនិង តាមសហករណ៍និងណា៎ ធ្វើនៅនិងផង ធ្វើនៅខ្លា ធ្វើនៅបៀតសាលាឃុំ ធំៗណាស់អ្នកគ្រូ ហើយស៊ីម៉ង់ទៅដឹកពីតាម៉ុកៗ តាម៉ុកកាលនិងខ្ញុំទៅធ្វើផ្ទះឲ្យតាម៉ុកទៀតណោះណា

កល្យានៈ ផ្ទះតាម៉ុកនៅបឹងតាកែវនិងណា លោកតាអ្នកធ្វើដែរ?

ជួនៈ និងហើយខ្ញុំទៅជួយធ្វើដែរណា៎ ហើយតាម៉ុកមួយថ្ងៃៗគ្រាន់តែខ្នុររាប់ឡានណា ដឹកចូលមកពីលិចមក យកមកគាត់ឲ្យហូបតាំងពីដូង តាំងពីខ្នុរទំ ចំណីរចំណុកគាត់ឲ្យហូបពេលដែលទៅធ្វើនៅនិង ហើយខ្ញុំមិនមែនមូលដ្ឋានទេ តែបងប្អូនខ្ញុំគេប្រធានកង គេមូលដ្ឋានអញ្ចឹងគេឲ្យខ្ញុំចេះលាប ចេះបូកអីនិងទៅជួយធ្វើគេ ជាងសំណង់ណា ផ្ទះតាម៉ុកនិងៗថ្ងៃដែលគេទំលាក់តាកែវ យួនចូលដល់តាកែវហើយនិងណា តាម៉ុកមិនដឹងជាដល់ណាទេ ទៅបាត់អស់តាំងពីថ្ងៃមុននិងណោះ តែជាងនៅធ្វើ ឡានហោះរជុំវិញផ្សារអញ្ចឹងទំលាក់ទៅ ខ្ញុំចេញពីផ្ទះតាម៉ុក កាត់វាលបឹងទៅដើងអញ្ចឹងទៅ មកឡើងសឹង្ហអញ្ចឹងមកហើយមកផ្ទះនៅអន្លុតានូណោះ ផ្ទះខ្ញុំនៅអន្លុតានូ

កល្យាន: អញ្ចឹងពេលដែលបែក៧៩និង ផ្ទះតាម៉ុកអត់ទាន់ធ្វើហើយស្រួលបួលទេ?

ជួន: នៅអារោងបាយ ខាងលិច កំពុងតែលាបកំបោរ អារោងបាយខាងលិចណាំ

កល្យាន: ផ្ទះនិងចាប់ធ្វើពីឆ្នាំណាលោកតា?

ជួន: ខ្ទង់....៧១-៧២និង

កល្យាន: ទេ មិនមែនទេលោកតា កាលនិងនៅលន់ណុលនៅឡើយទេ ៧៥ ប៉ុលពតឈ្នះ

ជួន: អើ អញ្ចឹងហើយ ហើយយើងបែក៨០ប៉ុន្មាន?

កល្យាន: យើងបែកវៀតណាម៧៩ ហើយ៧អាពតឈ្នះ ។ បែក៧៥បានប៉ុន្មានឆ្នាំគេឲ្យលោកតាទៅធ្វើផ្ទះតាម៉ុក?

ជួន: ចូលជិត៨០ហើយអ្នកគ្រូ ខ្ញុំថាអញ្ចឹង ៧៥ខ្ញុំចេញពីតាកែវមកបែក ហើយមកនៅនេះខ្ទង់៧៦-៧៧និង ហើយទៅធ្វើផ្ទះតាម៉ុកនិងសុទ្ធតែជាងស្រុក ជាងខេត្តអីមកធ្វើណាំ គេមកធ្វើនិងខ្ញុំកាលនិងខ្ញុំចូលខាងជាងឃុំទៅជួយលាបអីនិងណា

កល្យាន: លោកតាទៅនិង គេធ្វើបានអីខ្លះហើយឬនៅ?

ជួន: ធំហើយ នៅតែរោងបាយទេ

កល្យាន: អូ! លោកតាទៅក្រោយទេអញ្ចឹង?

ជួន: បាទ ទៅក្រោយទេ ជិតបែកហើយនិង មកឡានហោះមកទំលាក់នៅតាកែវហើយនិង ខ្ញុំទៅបានប្រហែលជាមួយអាទិត្យ គ្នាខ្ញុំ៤នាក់ប្រធានកងមួយណា ឥឡូវគាត់នៅរស់ទេ គាត់នៅប្រធានភូមិនៅទួលត្បែងឥឡូវនិងហេះ

កល្យាន: អញ្ចឹង?

ជួន: បាទ

កល្យាន: គាត់ឈ្មោះអី?

ជួន: តាហេង

កល្យាន: គាត់ប្រធានកងការងារនិងហេះ?

ជួន: បាទ ប្រធានកងការងារនិង តែគាត់ស្រួលដែរ គាត់អត់ចេះរាយការណ៍ពីមហាជន ពីអីអត់ទេ អត់ចេះរាយការណ៍ទេ

កល្យាន: មុនពេលដែលលោកតាទៅធ្វើផ្ទះតាម៉ុកនិង លោកតានៅនេះ លោកតាក្រៅពីធ្វើជួរធ្វើស្ពានលោកតាធ្វើអីទៀត?

ជួន: មុននិងទៅធ្វើផ្ទះតាម៉ុក ខ្ញុំធ្វើស្ថានីយនៅសាលាឃុំនេះ

កល្យាន: ស្ថានីយអី?

ជួនៈ ស្ពានឹយបូមទឹកនៅអូចំបក់ ធ្វើស្ពានឹយផង ធ្វើរោងបាយផង អារោងបាយនិង ចាក់សាបធ្វើលានស្រូវណាអ្នកគ្រូ

កល្យានៈ អញ្ចឹងនិយាយឲ្យចំទៅ លោកតានៅក្នុងក្រុមសំណង់

ជួនៈ បាទ ខាងជាងសំណង់ ដើរដាក់លូអីនិង ស្ពានព្រៃធាតុអីនិង អាចុះពីថ្នល់មកនិង ខ្ញុំធ្វើ តើ

កល្យានៈ ចេះតែដើរចុះពីមួយកន្លែងទៅមួយកន្លែងអញ្ចឹងទៅ?

ជួនៈ ហើយយាយធ្វើស្មុកឲ្យមួយ ដាក់ខោអាវនិង ហើយអញ្ចឹងវាគ្មានអីដណ្ដប់ទេអ្នកគ្រូអើយ មានតែក្រណាត់ប្រឡឹបយើងនិងណាំ ហើយគេឲ្យខោខ្មៅមួយរឹបចង្កេះនិងណា អាវអំណាចពីតាកែវនិងមកទេ យើងមានអីពាក់និងទៅណា ហើយចំណែកអង្គការកាលពីប៉ុលពតនិងគេអត់ដែលឲ្យអាវខ្មៅទេ ឲ្យតែអាវខ្មៅប្រឡឹប ហើយអាវសប្រឡឹបនិងគេឲ្យចង់ទៅជាខ្មៅទៀត អញ្ចឹងយាយខ្ញុំនិងដើររកស្លឹកគ្រស់ ស្លឹកឈ្មោះអីជ្រលក់ឲ្យតែខ្មៅ ដៃត្រឹមនេះ ដៃខ្លីនិងណាំ ហើយខោនិងក៏គេឲ្យខោសដែរ ខោនិងប្រឡឹប អ្នកគ្រូ អញ្ចឹងយាយខ្ញុំនិង គាត់យកទៅដាក់ស្លឹកគ្រស់ ស្លឹកឈ្មោះអីទៅ វាខ្មៅទៅណាំ។ តែស្បៀកចូល meeting អីម្ដងម្កាលនិង បានតែ២-៣ដងអីឡើងពណ៌ដែរនិង ប្រែពណ៌

កល្យានៈ អញ្ចឹងបានន័យថាលោកតាអត់សូវដែរនៅភូមិទេអញ្ចឹង?

ជួនៈ អត់ដែលនៅភូមិទេ ទាំងអស់ នៅតែកូនខ្ញុំហើយនិងម្ដាយនិងទេ គាត់នៅភូមិ។ ខ្ញុំទៅនៅតែតាមកងទេ

កល្យានៈ លោកតាប៉ុន្មានថ្ងៃទើបមកលែងភូមិម្ដង?

ជួនៈ មួយអាទិត្យ យាយខ្ញុំគាត់នៅភូមិបឹងណោះ គាត់ធ្វើកងចល័តណា មួយហិចតា៤នាក់អ្នកគ្រូមើល។ យាយខ្ញុំស្ទូងបានណា មួយហិចតា៤នាក់ណាំ គេអត់ឲ្យឈប់ទេ មានអ្នកលុញស្ទូ បញ្ចុកតាមក្រោយ មានគេរត់ការណ៍ណា ពេលដែលអង្គការគេអីចុះមកមើលនិងណាំ ប្រធានឃុំប្រធានស្រុកគេមកចុះមើលណា មកស្ទូងមានតែយាយខ្ញុំនិងប្អូនខ្ញុំមួយ ប្អូនជីដូនមួយ ហើយនិងនៅអង្គនរាយមួយ ៤នាក់និងមួយហិចតាហើយ

កល្យានៈ មួយថ្ងៃ?

ជួនៈ មួយថ្ងៃ មួយថ្ងៃមួយហិចតាណា ហើយស្ទូងគេកំណត់តែ៣តឹក។ ៣តឹកមួយដំណោតហើយអញ្ចឹងគេយកគេលុញហើយគេហុចឲ្យ ស្ទូយើង ស្ទូក្រហមនិងណាំ ហើយបាយថ្ងៃនិងគេស្ងួរគ្រួនអីប៉ូវទៅណា យាយខ្ញុំគាត់ធ្វើជាប់រហូតអត់សូវដែលបានមកផ្ទះទេយូរៗគាត់មកម្ដង ហើតម្ដាយខ្ញុំគាត់នៅចាំកូនខ្ចមនិង មានស្អី

កល្យានៈ គេឲ្យគាត់ធ្វើអីលោកយាយ?

ជួនៈ កាលនិងគាត់ជរា គេឲ្យគាត់មើលចៅឲ្យគេ ៤-៥អីយកមកទុកជាមួយគាត់អញ្ចឹងទៅ ណា៎ ម្តាយគេទៅវែកដីដឹបូកដិតភូមិនិងណា៎ កាលនិងនៅអន្គុតានូ នៅព្រៃធាតុនេះ អញ្ចឹងគាត់និងមើលកូនឲ្យគេ ទាញខ្សែអង្រឹងៗ អង្រឹងក៏គ្មានអង្រឹងនីឡុងអីដែរ ក្រមា និងណាអ្នកគ្រូ ក្រមា អាណាតូចនិងគេឲ្យអំបោះនិងមកធ្វើអង្រឹងណា៎ ២-៣ខែនិងណា នរណាដែលចេះដើរគេធ្វើអង្រឹងឬស្សីឲ្យ ដាក់ដេកក្នុងនិងទៅណា អញ្ចឹងគាត់ចេះតែ យោលទៅទំរាំតែម៉ែគេមកវិញម៉ោង១១ ហើយអាណាយំទៅ អាណាគេស៊ីអីគាត់ដើរ រកដំណាំក្នុងភូមិនិងកាយដីដុតឲ្យស៊ីទៅ អាណាចេះដើរចេះវានិងណាៗ ម៉ែខ្ញុំនិងគាត់ចេះ មើលអញ្ចឹងតើ ហើយខ្ញុំនោះនៅតែកងជាប់រហូត ទាល់តែដល់ថ្ងៃបែកតែម្តង

កល្យានៈ លោកតាធ្វើមេកងនិងឬកូនកងក្នុងក្រុមជាងសំណង់និង?

ជួនៈ ខ្ញុំអត់ទេ ខ្ញុំមានគេប្រធានកងនិង គាត់កាន់ការ ពីសង្គមគាត់ធ្វើការនៅភ្នំពេញ ធ្វើផ្ទះថ្ម ២-៣ជាន់អញ្ចឹងទៅណា អញ្ចឹងគាត់ប្រធានកងខ្ញុំផង ហើយដល់ហើយខ្ញុំនេះនៅក្នុងភូមិ និងគេសួររកថា នរណាចេះធ្វើជាងសំណង់ ចេះបូកចេះអី សុំលើកដៃ ហើយខ្ញុំក៏មិន ហ៊ានលើកដៃដែរ អញ្ចឹងគេថា អញ្ចឹងតាជួនឯង ខ្ញុំដឹងហើយ កាលពីសង្គមធ្លាប់ឃើញ ធ្វើការជាងសំណង់ដែរ អញ្ចឹងចូលជាមួយខ្ញុំៗ ដល់ខ្ញុំចូលមកគេឲ្យខ្ញុំមុនដំបូងធ្វើចាក់លូរ មានពុម្ពគេណា ពុម្ពនិងគេឲ្យប្រេងម៉ាស៊ីនដើរចាក់លូរអីឲ្យគេនិង ចាក់ចប់សព្វគ្រប់ទៅ ទើបលូរច្រើនទៅ ដើរដាក់តាមបំពង់ទឹក ដែលចេញពីស្ពានមក ត្រចៀកៗស្ពាននិងណា៎ ប្រឡាយតូចៗនិង ហើយដល់ហើយនិងទៅ គេឲ្យទៅធ្វើស្ថានីយបូមទឹកនៅអូរចំបក់ អានិងបូមទឹកពីអូរចំបក់និងសព្វស្រែម្តុំ............

Cassseete 1
Side B

កល្យានៈ ហើយលោកតាធ្វើការនៅកងអីអញ្ចឹង លោកតាបានរបបបាយឬមួយបបរ?

ជួនៈ បាយ កាលពីខ្ញុំទៅ ពេលព្រឹកគាត់បបរឲ្យហូប បបរលាយ កាលនិងនៅក្រណាស់អ្នក គ្រូ គេបបរលាយព្រលិត មួយខ្ទះអញ្ចឹងទៅគ្នា២៥នាក់និង ដួសចែកមួយចានៗម្នាក់

កល្យានៈ ខាប់ទេបបរ?

ជួនៈ បបរនិងខាប់ល្មមដែរ

កល្យានៈ អានិងពេលព្រលឹម ឬមួយថ្ងៃត្រង់?

ជួនៈ ពេលតែម្តង បាយតែម្តង ល្ងាចក៏បបរ ព្រឹកក៏បបរ ដល់យើងបន្តបន្ទើនដងក្នុងភូមិបាន ច្រើនទៅ គេឲ្យដាំដែរ តែដាំនិងបេះៗណាអ្នកគ្រូ អញ្ចឹងគេឲ្យយើងស្ទូ ស្ទូព្រលិត ត្រកួនអីទៅ ក្នុងកងនិង ហើយព្រលិតសេដ្ឋកិច្ចគេទៅដឹកឯអូរចំបក់មក ហើយកាលនិង វាគ្មានប្រហុកទេ មានតែអំបិល

សាវីណាៈ មានត្រីដែរអត់?

ជួនៈ បាទ ត្រីមាន ត្រីសេដ្ឋកិច្ចទៅបង់នៅបឹងតាកែវនិង

សាវីណាៈ លោកតាមានប្រសាសន៍ថា ពេលដែលចូលមកអញ្ចឹងគេធ្វើប្រវត្តិរូបលោកតា គេធ្វើ ប្រវត្តិរូបលោកតាដែរហេះ?

ជួនៈ គេធ្វើដែរ គេដើរធ្វើ ចុះកាលពីកាលពីនៅតាកែវធ្វើអី ហើយខ្ញុំកុហកគេយ៉ាងម៉ិចបើខ្ញុំ ធ្វើទាហាន ប្រាប់ថាទាហាន ហើយគេសួរថានៅ Battalion ណា ខ្ញុំថានៅ Battalion លោកសួងសក្តិ២ ខ្ញុំថាអញ្ចឹងណា

សាវីណាៈ គេធ្វើប៉ុន្មានដងលោកតា?

ជួនៈ គេធ្វើពាដងណោះ គេស្រាវជ្រាវជាប់

សាវីណាៈ ចុះពេលគេធ្វើម្តងៗគេធ្លាប់ហៅលោកតាទៅណែនាំអីទេ?

ជួនៈ ហៅដែរ ហៅទៅណែនាំរៀនសូត្រជាប់ ហើយគេសំគាល់ចរិតយើងអនុវត្តការងារ នរ ណាដូចថានិងគាត់អនុវត្តការងារ គាត់យកចិត្តទុកដាក់ហើយគាត់ស្មោះត្រង់ជាមួយនិង បក្សណា អង្គការគេហើយ អញ្ចឹងយើងមិនបាច់មកពិនិត្យគាត់ទៀតទេ ហើយប្អូនជីដូន មួយខ្ញុំនេះ នៅផ្ទះកើតនេះ គេឈ្លបដែរណាថា គាត់ស្លូតបូតទេ ចរិតគាត់ អានេះកុំ បន្ទោសគាត់អី គេលើកអញ្ចឹងណា អ្នកគ្រូខ្ញុំជំរាប់តិចទៅថា ប្អូនខ្ញុំនិងវាមានប្រាប់អង្គ ការនិងណា ឥឡូវកុំបន្ទោសគាត់អី គាត់រស់នៅកន្លែងណា សង្គមបំពាក់អញ្ចឹងហើយឲ្យ គាត់ធ្វើយ៉ាងម៉ិច ឥឡូវគាត់មករស់នៅជាមួយអង្គការយើងនេះ គាត់ស្មោះត្រង់ស្លូត ត្រង់អញ្ចឹងដែរ អញ្ចឹងកុំមកខឹងនិងគាត់អពេ្ចះអញ្ចឹងអី ឥឡូវទុកគាត់ឲ្យធ្វើការទៅ បំរើ ការងារអង្គការទៅណា អញ្ចឹងចាប់តាំងពីថ្ងៃនោះមក ខ្ញុំចេញទៅវាលជាប់ទៅ ហើយ ប្អូននិងវាដើរតាមវាលតាមកាលនិង ណេះលោបងឯងកុំនិយាយអីឲ្យសោះ ហើយ លោកបងឯងខំប្រឹងការងារអីបន្តិចទៅ ខំប្រឹងការងារៗ ខ្ញុំថារឿងការងារមិនបាច់អូន ឯងព្រួយទេ រឿងការងារ អង្គការដាក់ចុះធ្វើម៉ាន ចុះគោរពធ្វើនិងណា៎ ហើយខ្ញុំម្តង នោះទៅប្រជុំ មានគ្នាខ្ញុំសុទ្ធតែថ្មីណាអ្នកគ្រូ ថ្ងៃល្ងាចចេញពីប្រជុំមកវិញ ប្រធានឃុំគេ ជិះកង់តាមក្រោយ អាពួកម៉ាកខ្ញុំវារាងដូចជាលេងសើចច្រើន គេច្រៀងគោរពទង់ជាតិ

ប៉ុលពតនិង មហាមេទិញនៅវត្តបូរនេះ ចេញមកវិញហើយនាំគ្នាដើរ៣នាក់ទទូក្រណាត់សរនិងទាំង៣នាក់និងណា គេច្រើន មើអង្គការគេច្រៀងយ៉ាងម៉ិចម៉ិញជូន ខ្ញុំថាគោរពទង់បក្សគេម៉ិញនិង មហារុងរឿង មហាលោតផ្លោះ មហាអស្ចារ្យនោះ ហើយខ្ញុំថាអញ្ចឹងណា អញ្ចឹងអាសុនវាថា ហ៊ឺស! ទៅជឿអីអញ្ចឹង មហាហិនហោចមិនថា មហារុងរឿងអី វាថាអញ្ចឹង ៗ គ្រាន់តែថាអញ្ចឹង តាហូរដិះកង់ដល់កន្លែងនិងម៉ង គាត់ប្រធានឃុំណ៎ា យីតាជួនទើបតែដល់នេះទេហេះ បាទៗទើបតែដល់នេះទេ ភ័យ២ថ្ងៃណោះភ័យនោះភ័យ ទៅដេកវិញនៅតែភ័យ ៗ ហើយក្រោយមកទៅពិគ្រោះគ្នាជាមួយ អាសុនហើយអាសុននិងទៀត មកនៅនេះ វាធ្វើឈ្លប ដល់តែបែកមកវាធ្វើឈ្លបឃុំ ណ៎ាឈ្លបទៅបាញ់គេងាប់ជាប់គុកដល់ឥឡូវ ឥឡូវគេឲ្យធ្វើអ្នកយាមគុកនៅនិងទៅឥឡូវធ្វើស៊ីដង់គុកនៅនិងទៅ លែងមកផ្ទះទៅ គ្រួសារមកផ្ទះទៅ ហើយបានធ្វើធំទៅឥឡូវនិងណ៎ា យីតាហ៊ីគាត់ឲ្យធ្វើជាអ្នកយាមគុក អានិងអត់ចេះខ្លាចគេណា អានិងឆ្អិនក្បាលស៊ីក្បាល

កល្យាន: កាលពីគេហៅលោកតាទៅណែនាំពេលដែលទៅធ្វើប្រវត្តិរូមម្តង១និង គេណែនាំថាម៉ិចខ្លះពេលគេហៅទៅណែនាំ?

ជួន: គេណែនាំថា កាលពីដើមឡើយលោកតានៅលន់ណុល តាបំរើគេលន់ណុល ហើយឥឡូវមកចូលបដិវត្តណាលោកតា ខ្ញុំសុំជំរាបមិត្តយើងទាំងអស់គ្នាដែលមានពាក់ព័ន្ធនិងណ៎ា សុំបំរើការអង្គការយើងឲ្យបាន១០០% អង្គការយើងដាក់ចុះនូវមុនការងារអី ត្រូវមិត្តយើងទាំងអស់គ្នានិងគោរពផែនការនិង មិនត្រូវយកផែនការរបស់អង្គការយើងទៅជាន់ឈ្លីទេ អញ្ចឹងណា បើថាចង្អុរត្រង់ណាធ្វើត្រង់និង អត់មានថា មិត្តឯងចង្អុរថាឥឡូវទៅកាប់ដំបូកនិងហើយថាដំបូកនិងមានស្អីគេនៅកន្លែងនិងខ្ញុំមិនហ៊ានធ្វើទេ អត់ទេ អង្គការយើងអត់មានជំនឿអីអញ្ចឹងទេ ថាមានរោងអ្នកតាអី ៗ ឧទាហរណ៍ថាខ្ញុំមិនហ៊ានធ្វើទេលោកពូព្រោះដំបូកនិងមានអ្នកតានៅនិង អង្គការយើងអត់មានជឿអបិជំនឿអញ្ចឹងទេដាក់ត្រង់ណារលាយត្រង់និង អញ្ចឹងធ្វើទៅ អស់រោងអ្នកតាប៉ុន្មានហើយ វាវ៉ៃខ្ទេចកាលនិងវាស្រួលដែរ ៗ ខ្ញុំនិយាយរឿងមួយកាលពីខ្ញុំនៅបួស ខ្ញុំធ្វើវិហារមួយអត់បានបញ្ចុះសីមាទេ ហើយដល់ពេលខ្ញុំមកការកូនហើយបានកូនមួយនិង ដល់អាពតនិងម៉ង់អាពតគេចូលកាន់កាប់និង ដល់ពេលខ្ញុំមកធ្វើរោងបាយ មុននិងខ្ញុំមកធ្វើ គេហៅខ្ញុំទៅបូករោងបាយតាម៉ុកនិងណ៎ា គេឲ្យខ្ញុំទៅវ៉ៃវិហារវត្តបូរនេះ

កល្យាន: វិហារដែលលោកតាកសាងខ្លួនឯងនិង?

ជួនៈ បាទ កសាងខ្លួនឯងនិង អាពិដាននិងគេដាក់មីនណា៎អ្នកគ្រូ ដាក់មីនដាច់ខ្ទេចខ្ទីអស់រលីង ហើយព្រះអីបាក់របាក់អីអស់រលីង គេដាក់មីន២-៣គ្រាប់ណោះ ញ័រឡើងរតើដី ហើយដល់ហើយទព្វស្រុកគេមកដាក់គ្រិះនៅនិង គេវ៉ៃគោកាត់អាពិដាននិងណា៎ ហើយគេឲ្យខ្ញុំទៅវ៉ៃផ្ទឹមពេលអាពិដានធ្លាក់អស់ហើយនិង ញញួរ៥គីឡូ ទៅគ្នា៥នាក់ ហើយពិដានវិហារនិងមិនមែនទាបទេ ខ្ពស់ជាងចុងដូងកើតទៀត តែវាផុតពិដានទៅវាមានដែក៨នៅក្រឡុកអីចេះ ហើយខ្ញុំទៅវ៉ៃបៀតអាដែកក្រឡុកនិង វ៉ៃបានតែ៣ញញួរតើអ្នកគ្រូ រុញទំលាក់តែម្តងនិង រុញខ្ញុំណា ខ្ញុំស្រវាចាប់បង្គោលនិងបាន ធ្លាក់ស្តោកមកហើយនិង ចាប់ដៃជាប់អញ្ចឹងហេះ ញ័រឡើងទទ្រើក អញ្ចឹងឃុំគាត់ឃើញអញ្ចឹង ជួយជង១ គេចងខ្សែត្រង់នេះទំលាក់មកតែម្តង ចងពួក្រៀកណា ហើយឲ្យចាប់ពួរនិងចុះមកម្តងនិង ចុះមកដល់ដីណា ហើយពួរនិងកាបណា៎ ដាក់កង់ហើយវិលណាអ្នកគ្រូ និងហើយ ហើយអាអ្នកគោងចេះតែគោងទៅ គេបញ្ចុះខ្ញុំមកដល់ដីនិងម៉ង អញ្ចឹងខ្ញុំថ្វាយបង្គំប្រធានឃុំថា ខ្ញុំអត់ហ៊ានឡើងវ៉ៃទៀតទេលោកពូ ខ្ញុំសុំឲ្យតែលោកពូដាក់ការងារត្រង់ណាក៏ខ្ញុំគោរពដែរ ត្រង់និងខ្ញុំមិនហ៊ានឡើងវ៉ៃទៀតទេ។ អើខ្ញុំឃើញហើយត្រង់និងតាឯងឡើងទៅវ៉ៃញ័រអញ្ចឹង ដូចថាខ្ញុំមិនហ៊ានប្រើដែរ អញ្ចឹងតាទៅកងវិញទៅ ហើយដូរនណាដែលគេមានកម្លាំងមក ក្មេង១ទៅណា ហើយដូរក្មេង១យុវជនអាយុ១៧-១៨និងណា៎ មកវ៉ៃអា និង

កល្យាន: កាលនិងឆ្នាំណាលោកតា?

ជួនៈ កាលនិងកំពុងពេញធ្វើ ជិតបែកហើយ ជិតយួនចូលហើយ ៧៧-៧៨និង ហើយកាលនិងគ្នាខ្ញុំដេកនៅជាមួយគ្នានិង ដេកជាមួយគ្នាណា៎អ្នកគ្រូ វាអាវិទ្យុមួយតូចនិងណា អញ្ចឹងបុកធ្យូងដាក់ឡូត អា៦០និង អញ្ចឹងដេកបើកប៉ុស្តយួនថា រំដោះមកហើយ មកដល់ខាងត្បូងហើយនិង គិតនាំគ្នាប៉ុន្មានដណ្តប់នាក់នាំគ្នារត់ទៅយួនណា៎ ហើយដល់ពេលរកផ្លូវរត់ទៅយួន ខ្ញុំនេះទទួលគេធ្វើនំបញ្ចុក ហើយគ្នាខ្ញុំប៉ុន្មាននាក់និង លួចម្សៅនាំបញ្ចុកដុតណា ដុតរត់ទៅណា មានបានស៊ីនំនេះណា៎ គេឡើងមកហៅខ្ញុំថា យី! ខ្ញុំអត់ទៅទេ ខ្ញុំខ្លាច ទព្វគេយាមតាមផ្លូវ ទព្វគេដាក់ស្កាត់ អត់ទៅជាមួយគេទេ ឯងទៅក៏ទៅចុះ អញនៅចាំហែអើនេះចុះ ទៅគ្នា៦-៧នាក់ អត់មានឃើញមកវិញទេ។

កល្យាន: អញ្ចឹងគ្នា ៦-៧នាក់និងរត់ទៅ?

ជួនៈ បាទ រត់ទៅអត់មានឃើញមកវិញផង លុះឥឡូវនិងនៅភូមិប្រកន ជិត១ខ្ញុំដែរនិងហេះ ចោលប្រពន្ធមេម៉ាយនៅមានកូនអី នៅរាល់ថ្ងៃ

កល្យាន: អ៊ីគិតថាអ្នករត់ទៅនិងយ៉ាងម៉ិច ស្លាប់ឬយ៉ាងម៉ិច?

ជួនៈ បែបស្លាប់ហើយ បើរស់នៅឃើញហើយ បែបស្លាប់អស់ហើយព្រោះកាលនិងដេកជុំគ្នាថា យើងគិតទៅស្រុកយួនហេះៗ ហ្វែងទៅតាមណារួច បើយួននិងតាកែវនិងជាជិតគ្នាហើយនិង ហើយធ្វើការនៅអូរចំបក់នេះ ហើយកាំភ្លើងលឺសូវដល់និង កាំភ្លើងដៃនិងឡើងវើមកជិតដល់នេះហើយនិង ដល់ហើយខ្ញុំទៅមិនរួចទេ ឯងទៅក៏ទៅទៅ អញទៅមិនកើតទេ ទៅឯណាបើឈ្លបគេដាក់មួយយប់ៗគេរត់ស្បៀងនោះ ហើយអាសែងគ្រាប់និងឃើញដាក់ស្ពែងហើយនិង ហើយយើងទៅយ៉ាងម៉ិច ហើយប្រជាពលរដ្ឋី រត់មរគេករគាកដូចយើងបែក៧៥អញ្ចឹងណាំ រែកមករត់មកពីកំពង់ឈូកមកណា កំពង់ ឈូកទល់ដែននិង រត់មកប្អូនខ្ញុំអីមួយមួយពៅនិង យុវនារីគេរត់មកដែរនិង គេផ្លោង ពេកគេរត់ដកកងចល័តមុខនិង ដល់មកដល់តាកែវនិងគេឲ្យវាជញ្ជូនគ្រាប់អី យកទៅទប់យួននិងណា ហើយទប់មិនឈ្នះ ទប់ម៉ិចនិងឈ្នះ ទប់អត់ឈ្នះទេ មួយថ្ងៃកិលបន្តិចៗដែនការផ្តង់គ្រីបនៅក្នុងភូមិ គេថាឲ្យខំប្រូតឲ្យលឿនទៅ អន្តការយើងឲ្យប្រូត ប្រូតស្រូវនៅខ្ចី ប្រូតគគៗ ហើយមានបានបោកអីណា រត់ក្ទីង ខ្ញុំនិងរត់ ខ្លាចគេរត់ រត់រហូតដល់ភ្នំ១០០ស្រទាប់ណោះណាំ ហួសភ្នំដីរីរមៀលទៀត ផ្លូវជាតិលេខ៤ណោះណា

កល្យានៈ ពេលទៅនិងជុំយាយហើយនិងកូនដែរអត់?

ជួនៈ រទេះមួយបេះតែទៅនិង ម្តាយក្មេកនិង កូនចៅខ្ញុំនិង កូនខ្ញុំនិង ២នាក់និង ហើយយាយម្តាយនិង ដាក់រទេះទៅ ដឹកទៅរហូត ទៅដល់ភ្នំ១០០ស្រទាប់ ហួសប្រផង់ទៀត ឆ្ងាយណាស់ ផ្លូវជាតិលេខ៤អ្នកគ្រូ មើលទៅត្រលប់មកវិញខ្មែរក្រហមគេលែងគាំទ្រហើយ ណាំខ្ញុំបេះតែសៀរៗមក មកជួបឈ្លបគេគេដេញឲ្យទៅលិច ខ្ញុំថា ខ្ញុំមិនទាន់ទៅកើតទេព្រោះម្តាយចាស់ ខ្ញុំសុំស្នាក់នៅនេះ ដល់យប់ឡើងមានប្រជាពលរដ្ឋដែលយួនចាប់បាននៅម្តុំអស់និងហេះ ខ្ញុំយួនចាប់ទៅកសាងរៀនសូត្រអស់មួយអាទិត្យហើយ ហើយឥឡូវនិងស្រុកយើងដូចដើមវិញហើយ ឥឡូវបងឯងទៅតាមខ្ញុំៗ គេមានការគេមានស៊ីផឹកអី មានប៊ីចេងមានអី ប្រហុកអីហូបបរិបូរ

កល្យានៈ អញ្ចឹងលោកតាទៅនៅលិចនិងយូរហេះ?

ជួនៈ ទៅនៅមួយខែជាង អញ្ចឹងខ្ញុំបេះតែបរទេះសៀរយប់ៗណាំ សៀរៗមក ចូលយួនប៉ុបយប់ គេបាញ់នោះបាញ់ ពេលខ្ញុំចូលអញ្ចឹងគេបាញ់ទៅមុខណោះ ថាប៉ុលពតមកយកស្រូវ គេថាអញ្ចឹងណាំ ហើយខ្ញុំនិយាយប្រាប់គេថា ខ្ញុំមិនមែនមកយកស្រូវទេ ខ្ញុំប្រជាពលរដ្ឋរត់មកតាកែវ អញ្ចឹងគេថា ឱៗ គេឲ្យទៅ ទៅដល់នៅម្តុំគ្នាខ្ញុំនិងប្រហែលជា២០នាក់ៗ នៅម្តុំនិងទៅគេសួរពីមូលហេតុរត់និងណាំ ថាខ្មែរក្រហមដេញ ខ្ញុំបេះតែទៅៗ

ដល់ហើយគាត់ឲ្យអង្ករនិងប្រហែលជា១០គីឡូ ហើយគេឲ្យត្រីងៀតនោះប្រហែលជា២គីឡូ គេយកមកសួរប្រវត្តិរូបចប់សព្វគ្រប់ហើយគេឲ្យនៅម៉ុំ ហើយសម្ភារៈខ្ញុំទាំងប៉ុន្មាននិង គេសុំស្តាយណាំ គេសុំជួយ មាសអីគេដោះយកណា ដល់តែមានមេគេមកមួយ គេនិយាយយួនណាំ គេនិយាយយួនដាក់គ្នាគេ អញ្ចឹងដោះឲ្យវិញ ។ មាសយាយពាក់និង ម្តាយខ្ញុំការជាងមួយជីកន្លះ ចុះស្រុកយើងឯករាជហើយចេះតែពាក់ទៅណា ហើយប្អូនខ្ញុំនិងសុទ្ធតែមួយជំឡឹង១ ដាក់ក្នុងចង្កេះខោងនិងណាំ អញ្ចឹងវាអត់មានស្រាវជ្រាវយកអានិងទេ វាយកតែអាឃើញយើងពាក់នេះ ដល់ហើយវានិយាយចន្លុះមុខគ្នាវា វាហុចឲ្យវិញទៅ វាជញ្ជូនខ្ញុំមកដល់កន្លែង វាមើលជាប់រាល់ថ្ងៃ ៧ថ្ងៃទើបគេឲ្យមកភូមិនិង

កល្យាន: អញ្ចឹងក្នុងសម័យខ្មែរក្រហមនិង លោកតាមានសាច់ញាត្តិ បងប្អូនណាម្នាក់ត្រូវគេ សម្លាប់ គេធ្វើទារុណកម្ម ធ្វើបាបអីទេ?

ជួន: មានដែរ

កល្យាន: នរណាទៅ?

ជួន: តាខ្ញុំនេះ ឈ្មោះតាញ៉ែម តាញ៉ែមនិងពីដើមគាត់ធ្វើកាប៉ារាល់ថ្នល់ ដល់ពេលប៉ុលពតជិតបែកហើយនិងហេះ គាត់និយាយតែមួយម៉ាត់ទេ គាត់ថាស្លូត្រកួនវេង១អញ្ចឹងហើយអញអត់មានធ្មេញផងមិនដឹងជាស៊ីម៉ិចនិងបានទេ ថាអញ្ចឹងណា គាត់និយាយតែគ្នាគាត់ទេណា ដល់ហើយ ល្ងាចឡើងស្រាប់តែគេគេចាប់គាត់សែងដូចជ្រូកអញ្ចឹង ចងជើងផង រែងផង ស្លាប់បាត់ទៅ មិនដឹងជាយកចោលនៅកន្លែងណា

កល្យាន: សែងយកទៅតែម្តង?

ជួន: បាទ អញ្ចឹងក្នុងមួយពូជខ្ញុំនិងមានតែ២នាក់និង មានតែឪពុកខ្ញុំនិងតាញ៉ែមនិងទេ

កល្យាន: តាញ៉ែមនិងត្រូវជាម៉ិចនិងលោកតា?

ជួន: ត្រូវជាតា ហើយពីដើមគាត់ធ្វើកាប៉ារាល់ថ្នល់

កល្យាន: និងជិតបែកហើយនិង?

ជួន: ជិតបែកហើយនិង នៅតែប៉ុន្មានថ្ងៃទៀតនិង កាលនិងពីស្របក់និងបបួលដុតនំទៅយួន និងហើយខ្ញុំមិនហ៊ានទៅ ក្នុងកងខ្ញុំនិងសុទ្ធតែទាហាន ខ្លះគេធ្វើពេទ្យណាំ តាកបនេះអីសុទ្ធតែពេទ្យទាហាននិង សក្តិ១ណាំ ពួកខ្ញុំហើយនិង

កល្យាន: ខ្ញុំដូចជាអត់លឺលោកតានិយាយពីរឿងម្តាយ?

ជួន: ម្តាយខ្ញុំគាត់ស្លាប់មុនខ្មែរក្រហមទៀតណោះ ម្តាយខ្ញុំគាត់រៀបការឲ្យខ្ញុំអាយុ២១ ហើយដល់ពេលដែលខ្ញុំការហើយបាន៦-៧ឆ្នាំនិងណាំ អត់ទាន់មានកូនទេ គាត់ស្លាប់ទៅ

ស្លាប់និងគាត់បន្សល់ទុកកូននៅលើវ៤នាក់ នៅបន្ទុកលើខ្ញុំនិងឪពុកខ្ញុំនិងណា៎ ហើយកាលពីគាត់ស្លាប់និង ប្អូនពៅខ្ញុំនិងទើបតែអាយុ៦ឆ្នាំទេ

កល្យាន: គាត់ស្លាប់និងជំងឺហេះ?

ជួន: បាទ ស្លាប់និងជំងឺ បើតាមការពិតទៅបែបចាស់ទេម្ដាយខ្ញុំ គាត់ចេះតែស្គមៗទៅ ហើយថ្នាំលេបមិនត្រូវណា៎

កល្យាន: ចុះពេលដែលវៀតណាមវ៉ៃចូលឆ្នាំ៧៩និង កាលនិងលោកតានៅកន្លែងណា?

ជួន: វ៉ៃបែកនិង ថ្ងៃនិងខ្ញុំនៅផ្ទះតាម៉ុក

កល្យាន: រយៈពេលធ្វើការផ្ទះតាម៉ុកនិង មានដែលឃើញតាម៉ុកអត់?

ជួន: អឺមិនឃើញ

កល្យាន: គាត់ទៅនិងញឹកអត់?

ជួន: ថ្ងៃណាក៏ឃើញដែរ នៅនិងគ្នានិង

កល្យាន: គាត់នៅលើផ្ទះនិងម៉ងហេះលោកតា?

ជួន: គាត់ចេញចូលៗមិនសូវឃើញនៅ ឡាន Jeep មួយគាត់មកជាប់រាល់ថ្ងៃនិង

កល្យាន: គាត់ជិះ Jeep?

ជួន: បាទ

កល្យាន: ហើយមានអង្គរក្សប៉ុន្មាននាក់?

ជួន: អង្គរក្ស២នាក់ ហើយមានកូនក្មេងមួយតូចបើកឡាន

កល្យាន: គាត់និងកាចទេលោកតា?

ជួន: ទេបើតាមខ្ញុំស្ដាប់សំដីគាត់ម៉ឺងម៉ាត់តែការងារទេណា៎ បើសំដីចំពោះប្រជាពលរដ្ឋអឺមានសីលធម៌ដែរ

កល្យាន: គាត់អាចារ្យដែរតើ?

ជួន: គាត់អាចារ្យដែរ អញ្ចឹងគាត់និងរឿងស្អើងខ្ពស់គ្រួតតិច មុខគាត់ស្រួចតិច ខ្ញុំនៅមើលគាត់ដែរនិង គាត់បញ្ជាឲ្យអាត្រាក់កាយដើមអំពិលទឹក៣អោប ហ្នែងមិនរុញមើល ដល់ហើយគ្នាលើកដៃនិងរុញ ហើយដួល ឥឡូវឲ្យអាម៉ាស៊ីនមកកាត់មេយឲ្យអស់ទៅ ហើយហ្វែងគាស់គល់និងមកចោលនៅឆ្ងាយៗទៅ គាត់ថាអញ្ចឹងណា ហើយគ្នាធ្វើម៉ិចនិងបានដូចចិត្ត គប់សុទ្ធតែដុំថ្ម តាម៉ុកមិនធម្មតាទេ បញ្ញាតឹងអញ្ចឹងណា៎

កល្យាន: អូ! ធ្វើការអត់ដូចចិត្តយកដុំថ្មគប់?

ជួនៈ បាទ គប់អាអ្នកឡើងនិងណា៎ ដុំថ្មប៉ុនៗមេដៃ គ្រួសមកចាក់លើថ្នល់ គ្រួសក្រហមនិង គាត់ជីងពីភ្នំថ្មក់មកណា៎ យកមកធ្វើជីវិញរោងបាយនិង ដាក់សុទ្ធតែគ្រួសក្រហមនិង អញ្ចឹងបញ្ជារអញ្ចឹង ឡានគគ្រឹងគគ្រេងឡានមកមួយថ្ងៃៗ សុទ្ធតែព្រៃនិង ឈូសចោល

កល្យានៈ ចុះពេលដែលពេលបែកហើយលោកតារត់នោះ លោកតាសាក់រំលឹកហេតុការណ៍និងមក លោកតា? លោកតាធ្វើអី ហើយរត់យ៉ាងម៉ិច?

ជួនៈ និយាយពីរឿងរត់ពីផ្ទះតាម៉ុកមកខ្ញុំមកភូមិ

កល្យានៈ ពេលនិងម៉ោងប៉ុន្មានលោកតាចាប់រត់ពីនិង?

ជួនៈ ម៉ោង ៩-១០ ព្រឹក

កល្យានៈ កំពុងតែធ្វើអីកាលនិង?

ជួនៈ ខ្ញុំកំពុងតែរែទឹកកំបោរ រោងបាយនិង ហើយរត់កាត់ពីវត្តខ្សឹងមកៗ មកដល់ភូមិម៉ោង ១១គត់ មកដល់យាយម្ដាយខ្ញុំនិងមកមូលគ្នាមកផ្ទះអស់ហើយ អញ្ចឹងឡានហោះមកពី ទំលាក់ពីតាកែវនិង មករេអស់និង ទំលាក់ទួលខ្ពស់នេះ អញ្ចឹងគេថាឡានហោះមកហើយ អត់ហ៊ាននៅទេ នាំគ្នាទៅវត្តសូរដើងណោះ ។ ចេញពីវត្តសូរមកនៅភូមិនិងវិញបាន២ យប់ ភូមិអន្គតានូវនោះ ចេញពីអន្គតានូទៅ ទៅលិចថ្នល់រហូត ចេញទៅលិចទៅៗ ចេញច្រើនទៅណា៎ អញ្ចឹងយួនស្កាត់អត់ទាន់ ខ្ញុំទៅហួសមុខខ្សែត្រៀមគេនិង ចេះតែ ទៅៗ ដល់ផ្លូវជាតិលេខ៤ ដល់ហួសភ្នំ១០០ស្រទាប់ណោះ ។ ដល់តែទៅដល់និងថ្ងៃ ពេញបូរមីខែចែត្រខ្ញុំមានជួបគេរត់រួចពីយួនចាប់បានទៅរៀនសូត្រ អញ្ចឹងគេថាអត់អីទេ ឲ្យតែបងប្អូនយើងត្រលប់ទៅស្រុកវិញទៅ ស្រុកណាទៅនិងវិញទៅ អញ្ចឹងខ្ញុំបានទទួល ពត៌មាននិងបាន មកជាមួយគាត់និងហេះ មកពេលយប់ គាត់ទៅដល់កន្លែងខ្ញុំនៅភ្នំ ១០០ស្រទាប់ ម្ដាយខ្ញុំគាត់កំពុងតែដាំបាយថ្ងៃល្ងាចម៉ោង៤ ដាំបាយជាត់ក្រោមដើម សក្រាំ ខ្ញុំនៅចាំដែរ ហើយស្វាយបៀតនិងប៉ុនៗមេដៃ កដើង ជ្រុះច្រើនណាស់អ្នកគ្រូ អើយ មិនរើសទេ ស្វាយព្រៃណា៎ ជ្រុះច្រើនណាស់ កូនខ្ញុំដើរម៉ិញនិង វារើសទាំងថ្នក់ ទាំងថ្នក់ វាជ្រុះណា៎ តែផ្អែមដែរនិង ហើយម្ដាយកំពុងតែដាំបាយអញ្ចឹងខ្ញុំថា តោះម៉ែ លើកបាយដាក់រទេះទៅ យើអត់ទាន់ឆ្អិនផង យើកុំគិតហូប យើងគឹតបរមួយយប់និងបរឲ្យ ដល់ថ្នល់ជាតិលេខ៣តែម៉ង អញ្ចឹងលើកដាក់ហើយចេញមកតែម្ដង ខ្ញុំទឹមរទេះមកម៉ង ផ្លូវវាត្រង់ណាអ្នកគ្រូ ខាងត្បូងភ្នំស្រង់ណា ចេញមកផ្លូវនិងណា៎ អញ្ចឹងមកមកឡើងមាន ផ្លូវមួយវត្តមួយនៅខាងត្បូងភ្នំស្រង់ ឡើងនៅនិង ឡើងថ្នល់ជាតិណា មកដល់ជិតថ្នល់ ជាតិជីជិត២គីឡូ យួនព័ទ្ធជាប់ ។ វាថាប៉ុលពតៗ យួនវាថាអញ្ចឹង ខ្ញុំថាខ្ញុំមិនមែនប៉ុល

ពតទេ ខ្ញុំប្រជាពលរដ្ឋទេ ឪៗ គេឲ្យទៅហើយណា មានអានោះមួយរត់មកទៀត រត់មកទៀត រត់មកជុំសុទ្ធតែកាន់កាំភ្លើងនិងណា៎ ហើយកូនខ្ញុំមីងនិងនៅលើរទេះ ហើយខ្ញុំឈប់គោចំស្ពាន គេដាក់បេការ៉ែងមួយអញ្ចឹងទៅទូទាំងៗវាបាញ់ទៅលិចណា៎ ខ្លាចខ្មែរក្រហមតាមកណា ដល់ហើយទើបគេទៅយកការណោះ អញ្ចឹងគោខ្ញុំហក់ពីលើស្ពានទៅ ខ្ញុំស្មានតែងាប់កូនហើយ ហក់ទាំងរទេះទៅវាដ្អើលគ្រាប់ ស្ពាននិងវាវែងតែទាបណាអ្នកគ្រូ ស្ពាននិងប៉ុលពតគេធ្វើស្ពានស៊ីម៉ង្ដណា៎ វាគ្រាន់តែងាកអញ្ចឹងទៅ ហក់ប្រាវអញ្ចឹងទៅ ស្ពាននិងវាអត់មានបង្កាន់ដៃណា៎ ហក់ទៅធ្លាក់ក្នុងប្រឡាយនិងដាច់ខ្ទេចកង់ ម៉ត់ ហើយខ្ញុំទុកចោលនៅនិងទៅ ហើយគេឲ្យយកអង្ករដាក់លើរទេះកងជ្រុញរបស់ប្អូនដែលមកជាមួយគ្នានិងណា៎ ដាក់លើនិងទៅ ដាក់បរទៅៗ ដល់បរបានតែបន្តិច អង្ករនិងវាធ្ងន់ឆេះ វាគូតដែកនិងឈើនិង ឆេះសំពោងទៅ ហើយនាំគ្នាបានទឹកមួយប៊ីដុងមក ជ្រលក់ដូតៗ ជាមួងយាយល្អៗនិងយកទៅជ្រលក់អានិងឆេះខ្ទេច គ្មាននៅសល់ទេ តែប៉ុណ្ណោះបានរស់ហើយ ឆេះអីណាឆេះទៅ ដល់ហើយ អស់ជាមួងនិង បានអាហូលមួយទៀត ជាមួយចង្កៀនរបស់ម៉ែផងណា

កល្យាន: អានិងលាក់បានទៀតលោកតា?

ជួន: លាក់បានស្អី យកទៅជ្រលក់ទឹក យកលាបជុំរទេះនិង វាកូតដែក កងនិងវាវិលទៅវាគូតឈើនិង វាក្តៅទៅ ឆេះតែមួងនិង ទំរាំតែដល់ថ្នល់ជាតិអស់ជាមួងមួយ អាចង្កៀននិងអាល្អពីដើម របស់ម៉ែ យកទៅជ្រលក់ទឹកអាក្នុងប៊ីដុងនិង យកទៅពូតដាក់១២-៣ជុំនិង ចេញភ្លើងហើយ អានិងកង់ដោតគ្រាប់ប៉ុណ្ណឹង អាយកធ្វើប៉ុនជុំទេះនិងម៉ង បោះទៅដាក់បំពង់ទីបមួយ វ៉ៃផ្ទុប់គ្នាទៅ ដាក់ដែកគោលខ្វះមកណា៎ អញ្ចឹងវាវិលដាប់ ហើយអាកណ្តាលនេះយើងធ្វើអញ្ចឹងទៅ ជុំនិងវានៅនិង វាវិលជុំនិង ហើយដល់យូរវិលចេញភ្លើងតាមនិង ឆេះអានិង ហើយដល់ឆេះអានិង យកជាមួយម៉ែពីរកញ្ចប់មកជ្រលក់ទឹកប៊ីដុងហើយយកពូតដាក់ ដល់ពូតយូរៗទៅ ណាអាយួនវាដេញផងអីផង យកទៅសង្កត់លើនិងផង យូរទៅឆេះទៅ អស់ជាមួងចង្កៀនគាត់មួយ ជាមួយករទាទៀតណា៎

កល្យាន: រហូតមកដល់ឥឡូវ លោកតាយល់ថារបបខ្មែរក្រហមនិងយ៉ាងម៉ិចដែរ?

ជួន យី! ខ្ញុំកុំឲ្យមានលើកទី២តទៅទៀត ខ្ញុំរៀងចាលហើយអ្នកគ្រូ សព្វថ្ងៃនេះបានសម្តេចលោករំដោះមកអញ្ចឹងខ្ញុំអរគុណសម្តេចខ្លាំងណាស់ ឃើញថាបានដូចដើមវិញហើយ មិនត្រឹមតែហូបចុះទេ មានដល់ផ្ទះសំបែង មានជីវភាពរស់នៅវាធូរធា មានដល់កង់ ម៉ូតូ

មានដល់គោលេចក្បាល អត់ទេថាកុំឲ្យមាន ថាស្អប់ខ្ពើមអញ្ចឹងម៉ងទៅណាអ្នកគ្រូ កុំឲ្យការវិលត្រលប់មកវិញ

កល្យាន: អញ្ចឹងលោកតាយល់ថាតើធ្វើយ៉ាងម៉ិចដើម្បីកុំឲ្យរបបនិងកើតមកវិញម្តងទៀត?

ជួន: យើងព្រួតដៃគ្នារាល់ថ្ងៃអញ្ចឹងទៅ ឲ្យអស់លោកណាដូចថាសម្តេចហ៊ុនសែនអញ្ចឹងទៅ គាត់បានរំដោះយើង អញ្ចឹងយើងជួយលើកស្ទួយទៅឲ្យគាត់ជួយការពារកុំឲ្យខ្មែរក្រហមនិងកើតបានជាពីរដងទៀតទៅ ឲ្យវារលាយបាត់ទៅ អញ្ចឹងភូមិខ្ញុំទាំងមូលនេះៗ ខ្ញុំមិនធ្វើនយោបាយទេអ្នកគ្រូ បើបោះឆ្នោតលើសគេហើយភូមិខ្ញុំ លើសគេជានិច្ច

កល្យាន: លោកតាធ្លាប់គិតថារឿងរ៉ាវកាលពីរបបខ្មែរក្រហមនិង វាយុត្តិធម៌អត់សំរាប់លោកតាសំរាប់បងប្អូនលោកតា សំរាប់ប្រជាជនទាំងអស់?

ជួន: ខ្ញុំថាមិនយុត្តិធម៌ បានខ្ញុំថាមិនយុត្តិធម៌ អ្នកគ្រូមើល ស្រូវល្អខ្លាំងណាស់ណាអ្នកគ្រូ ដឹងបូកដាក់ទៅល្អខ្លាំងណាស់ ដល់ពេលបានមកគេមានឲ្យយើងហូបបាយណា៎ ហូបបបរសូមជំរាបអ្នកគ្រូតែប៉ុណ្ណឹងទេ អញ្ចឹងស្រូវធ្វើបានគេដឹកឃុំ មិនដឹងជាយកទៅដោះដូរដល់ណា៎ ចិនណាណោះឡានដឹងរង្កើផ្លូវហើយមួយយប់ៗ គេឲ្យយើងហូបតែបបរទេ អញ្ចឹងចាប់ពីខែប្រាំង យើងខែបុស្សមាឃអញ្ចឹងនៅស្រូវគេឲ្យយើងហូបប៉េះៗហើយណាអ្នក គ្រូដល់ពេលចាប់ពីខែយើងភ្ជុំនិង អានិងសុទ្ធតែបបរហើយ បបរទាំងអស់ ឲ្យយើងហូប បបរបើសិនជាថាស្រូវធ្វើឃុំណាហើយភូមិនិង ហូបមិនអស់ទេ សង្កមនិងទាស់តែធ្វើការខ្ញុំមិនស្តាយគេកម្លាំង តែឲ្យហូបឲ្យឆ្អែតទៅខ្ញុំបានហើយ ហើយដេកស្រួលទៅ បើឲ្យគ្នាដេក ខ្ញុំអើយគោលីនក្តលទៅ គ្មានកន្ទេលដេកទេអ្នកគ្រូ កាច់ស្លឹកឈើក្រាលអញ្ចឹងហើយទំលាក់អញ្ចឹងមកណា៎ ហ្នឹយអាស្មុកយាយដាក់ទៅ ខោអាវតិចៗផ្លាល់ខ្លួននិងណាកើយ ហើយកន្សែងប្រឌឹប ក្រណាត់ប្រឌឹបមួយគ្រប....................

Cassette 2
Side A

កល្យាន: តែមួយចានទេ?

ជួន: បាទ មួយចាន

កល្យាន: មួយចាននិងពេញចានអត់?

ជួនៈ មួយចាននិងមិនពេញស្រួលទៀត ល្មមទេ

កល្យានៈ លោកមានធ្លាប់លឺគេនិយាយពីរឿងតុលាការខ្មែរក្រហមដែរអត់?

ជួនៈ ខ្ញុំមានលឺ មិនសូវបានស្តាប់ទេអ្នកគ្រូសូមអភ័យទោស ខ្ញុំលឺសូគេកាត់ទោសខ្មែរក្រហមអីអញ្ចឹងដែរណា ក្នុងវិទ្យុ

កល្យានៈ លឺយូរហើយឬនៅ?

ជួនៈ លឺពីឆ្នាំទៅម៉ិញដែរនិង

កល្យានៈ ហើយឥឡូវតុលាការនិងកើតហើយឬនៅ?

ជួនៈ មិនទាន់បានដឹងដែរអ្នកគ្រូ ការងារនៅវត្ត

កល្យានៈ តាមពិតអត់ទាន់កើតទេ ហើយលោកតាមឆ្ងល់ដែរអត់ថាលឺយូរហើយ ហើយម៉ិចក៏មិនទាន់កើត លោកតតាមឆ្ងល់ដែរអត់?

ជួនៈ ខ្ញុំឆ្ងល់ត្រង់និងដែរ

កល្យានៈ តាមពិតតុលាការនិងវាកំពុងតែដំណើរការ ហើយរំពឹងថាកើតក្នុងពេលឆាប់ៗនិងណាលោកតា តាមគំរោងតុលាការកើតមកនិងគេនិងកាត់ទោសមេដឹកនាំប្រទេស ប៉ុន្តែខ្ញុំចង់សួរពីគំនិតលោកតាវិញ តើលោកតាគាំទ្រឲ្យមានតុលាការនិងឬអត់?

ជួនៈ អត់ទេអ្នកគ្រូ អត់មានគាំទ្រឲ្យមានខ្មែរក្រហមអីទេអ្នកគ្រូ

កល្យានៈ តុលាការនិងមិនមែនគាំទ្រឲ្យមានខ្មែរក្រហមទេលោកតា គឺយើងកាត់ទោសអ្នកដឹកនាំខ្មែរក្រហមនិង?

ជួនៈ បាទ ខ្ញុំគាំទ្រដែរ បើសិនជាកាត់ទោសខ្មែរក្រហម ខ្ញុំជួយគាំទ្រ បើជួយកាត់ទោស

កល្យានៈ អញ្ចឹងលោកតាយល់ថា មេដឹកនាំខ្មែរក្រហមនិងគួរទទួលការកាត់ទោស?

ជួនៈ បាទ គួរតែកាត់ទោស

កល្យានៈ ហេតុអីលោកតា?

ជួនៈ ចុះបើបានជាខ្ញុំថាគួរណាតែកាត់ទោសព្រោះអីគាត់មកបំផ្លាញអ្នកចេះដឹងតាំងពីគ្រូអី គាត់មិនធ្វើដោយដៃមែន តែគាត់បញ្ជាអី បញ្ជាវត្តដូចជាគ្រូខ្ញុំអី អស់រលីង វត្តលាយបូរសុទ្ធតែអ្នកគ្រូធំៗផង អស់រលីង គ្រូបានបង្រៀនខ្ញុំទាំងប៉ុន្មាននិងអស់ សម្លាប់អស់ គ្រូខ្ញុំ៦-៧នាក់

កល្យានៈ អញ្ចឹងអ្នកដែលនៅក្រោមៗដែលសម្លាប់ផ្ទាល់ដៃនិង លោកតាចង់កាត់ទោសពួកគេដែរអត់?

ជួនៈ អាអ្នកនៅក្រោមដៃនិង ខ្ញុំចង់កាត់អាអ្នកផ្ទាល់ដៃនិងដែរនិង តែវាអត់មាននៅ អត់ដែលឃើញ តែបើឃើញមកនៅស្រុកនេះអត់ដែលឃើញទេ ក្នុងភូមិខ្ញុំអត់មានឃើញទេ តែខ្ញុំអត់មានបានដឹងថានរណាគេដៃដល់ទេណាអ្នកគ្រូ ខ្ញុំអត់បានដឹងទេ តែបញ្ជាមុខតែពីថ្នាក់លើមកហើយបានជាហ៊ានធ្វើនិង

កល្យានៈ លោកតាមានដែលធ្លាប់លឺគេនិយាយពីរឿងផ្សះផ្សាដែរអត់?

ជួនៈ បាទ និយាយដែរ ផ្សះផ្សាបង្រួបបង្រួមជាតិ ខាងយើងនិងណា?

កល្យានៈ មានន័យថាម៉ិចទៅលោកតាការផ្សះផ្សាបង្រួបបង្រួមជាតិ?

ជួនៈ ផ្សះផ្សាបង្រួបបង្រួមជាតិនិងមានន័យថា ឲ្យយើងចេះស្រលាញ់គ្នា ចេះរួបរួមគ្នាធ្វើការបំរើប្រជាពលរដ្ឋក្នុងប្រទេសទាំងមូលនិងឲ្យបានល្អនិងណាអ្នកគ្រូ

កល្យានៈ ចុះយុត្តិធម៌មានន័យថាម៉ិចលោកតា?

ជួនៈ យុត្តិធម៌ដាក់ស្តែង

កល្យានៈ មានន័យថាម៉ិចយុត្តិធម៌ដាក់ស្តែងនិង?

ជួនៈ ដាក់ស្តែងនិង ដូចជាសម្តេចហ៊ុនសែន ច័ន្ទសារុនអី លោកចុះមកធ្វើការផ្ទាល់ខ្លួនបំរើប្រជាពលរដ្ឋអញ្ចឹងនិងយុត្តិធម៌ហើយ ដូចថាគាត់ដឹកប្រឡាយឲ្យ អង្ករដល់ប្រជាពលរដ្ឋអញ្ចឹងទៅណាអ្នកគ្រូ ហើយគាត់ថាហើយ គាត់ឲ្យ អញ្ចឹងប្រឡាយតាមថ្នល់ជាតិនិងសម្តេចហ៊ុនសែនលោកមកនាំប្រជាពលរដ្ឋមកនិងគាត់ថា ឥឡូវប្រឡាយនិងយើងត្រូវស្តារឡើងវិញ ឥឡូវស្តាខ្ញុំត្រូវពឹងលើកម្លាំងប្រជាពលរដ្ឋទាំងមូល ធ្វើទៅ ខ្ញុំជូនជាអង្ករហូបអញ្ចឹងទៅ មានអង្ករអីគាត់ឲ្យហូបគាត់ទៅ

កល្យានៈ អញ្ចឹងសំរាប់លោកតាពាក្យយុត្តិធម៌មានន័យថាអញ្ចឹងហេះ?

ជួនៈ បាទ

កល្យានៈ លោកតាឧទាហរណ៍ថាឥឡូវនិងក្នុងភូមិនិងមានខ្មែរក្រហមនៅរស់ តើលោកតាគិតថាវវាងដែលប្រជាជនដែលនៅរស់និងខ្មែរក្រហមនិង តើអាចនៅជាមួយគ្នាយ៉ាងសុខស្រួលដែរអត់?

ជួនៈ ទេ បើតាមខ្ញុំសំលឹងមើលទៅអ្នកគ្រូ វាមានគំណាងកងអីអញ្ចឹង អញ្ចឹងបើតាមខ្ញុំពិនិត្យជាក់ស្តែងអានេះសង្កមបំពាក់ មិនដឹងធ្វើម៉ិច យើងសុទ្ធតែអ្នកធម៌អ្នកអាថ៌ដូចគ្នា អានេះសង្កមបំពាក់ទៅហើយយើងកុំខឹងអី ធ្វើម៉ិចទៅ យើងទុកជាអាសារបង់ទៅចុះ បើដូចជាឪពុកខ្ញុំជាដើមដែលគេសម្លាប់និង បើតាមខ្ញុំដឹងខ្វះៗទៅ ដឹងដែរ តែយើងមិនត្រូវសងឈាមគេវិញទេ ធ្វើម៉ិចទេ សង្កមគេបំពាក់ទៅ យើងកុំឲ្យមានដូចថា មានជាលើកទីពីរ

បើយើងគុំទៅ ដូចថាខ្ញុំដឹងថាអ្នកគ្រូហើយ ឧទាហរណ៍ណា ពេលស្រុកយើងមានសន្តិភាពត្រឹមត្រូវ ហើយខ្ញុំទៅធ្វើបាបអ្នកគ្រូវិញ អានិងខ្ញុំថាមិនទេ កុំឲ្យមានកម្មមានពារ៍អីឲ្យស្ងាត់ត្រឹមនិងចុះ ធ្វើម៉ិចសង្គមវាបំពាក់ណាស់ តែពីនេះតទៅកុំឲ្យមានសង្គមនិងកើតឡើងវិញណាអ្នកគ្រូ

កល្យាន: ពាក្យថាកម្មពារ៍មានន័យថាម៉ិចលោកតា?

ជួន: កម្មពារ៍គឺយើងចងកម្មចងពារ៍និងគ្នានិង

កល្យាន: លោកតាឧទាហរណ៍មើល ថាចងកម្មចងពារ៍និងយ៉ាងម៉ិចទៅ?

ជួន: ចងកម្មចងពារ៍និងដូចខ្ញុំឧទាហរណ៍ប្រាប់អ្នកគ្រូម៉ិញហើយ ដូចកាលអ្នកគ្រូនិងសម្លាប់ឪ ពុកខ្ញុំដល់ពេលស្រុកយើងបានសន្តិភាពស្រួលបួលទៅ មិនចងពារ៍និងអ្នកគ្រូទេ ទុកឲ្យអ្នកគ្រូរកស៊ីអាជីវកម្មតាមដំណើរអញ្ចឹងទៅ ធ្វើម៉ិចទេតាមកម្មផលរបស់គាត់ ត្រូវកម្មផលរបស់គាត់ត្រូវគេសម្លាប់ហើយធ្វើម៉ិច អញ្ចឹងខ្ញុំមិនចងកម្មពារ៍និងអ្នកគ្រូទៀតទេ

កល្យាន: ដូចឧទាហរណ៍លោកតាលើកឧទាហរណ៍ម៉ិញ ឧទាហរណ៍ថាខ្ញុំសម្លាប់ឪពុកលោកតា តែលោកតាអត់ចងពារ៍ខ្ញុំទេ តែបើតាមផ្លូវធម៌វិញតើខ្ញុំទទួលកម្មរបស់ខ្ញុំយ៉ាងម៉ិច?

ជួន: និងហើយទទួលកម្ម ទទួលថា អ្នកឯងសម្លាប់ជីវិតគេហើយ អ្នកឯងជាតិក្រោយត្រូវទទួលផលកម្មនិងទៅ មិនដឹងទៅកើតនិងស្អីទេ សម្លាប់មនុស្សមួយទៅហើយ

កល្យាន: កម្មនិងទទួលជាតិក្រោយ ជាតិនេះអត់ទេអញ្ចឹង?

ជួន: បច្ចុប្បន្ននិងអត់ទេ ក្នុងបច្ចុប្បន្ននេះវាធ្វើដែរ ជាតិក្រោយទៅ ចុះសម្លាប់ជីវិតគេមួយទៅហើយ អញ្ចឹងបានជាព្រះលោកបញ្ញត្តិ បាណា តេ បាតា វាចានៅសម្លាប់សត្វ អានិងឧទាហរណ៍ធម៌ព្រះហើយណាស់

កល្យាន: ចុះបើអ្នកនិងដូចជាមិនខ្វល់ថាជាតិក្រោយមិនដឹងទៅជាស្អីទៅ គេមិនដឹង គេដឹងតែថាជាតិនេះនៅដោយសុខស្រួល បានន័យថាគេរួចកម្ម?

ជួន: មិនរួចទេ កម្មណាដែលខ្ញុំធ្វើគឺថាមិនរួចដែរម្តង វានៅសោយទៅមុខទៀតទាល់តែបាន និងកម្មណាដែលខ្ញុំធ្វើអញ្ចឹងព្រះពុទ្ធលោកដាក់មកធ្វើអី អញ្ចឹងកម្មណាដែលខ្ញុំធ្វើអាក្រក់លើមាតាបីតាពិត ឬព្រះពុទ្ធពិតនិងវាទៅនិងហើយ

កល្យាន: តើលោកតាយល់ថា ធម៌ព្រះពុទ្ធអាចជួយអីខ្លះដល់សង្គមខ្មែរយើងលោកតា ធម៌ពារ៍រំងាប់ដោយការមិនចងពារ៍ ទស្សនៈកម្មផល អីនិង តើអាចជួយអីខ្លះ?

ជួន: លោកគ្រាន់តែហាមថា ឲ្យយើងសង្កត់ឲ្យបានទោស មោហៈ ដឹងទេអ្នកគ្រូ ទោសៈកុំឲ្យវាកើតឡើងណាស់ និងហើយធម៌ព្រះពុទ្ធលោកសំដែងតែប៉ុណ្ណឹងថាឲ្យគាត់ស្ងប់ អញ្ចឹងមិន

ខុសអំពីគេសូត្រថ្វាយបង្គំពេលព្រឹកនិង ចាំស្តាប់មើល គ្មានអ៊ីនិងស្មើនិងធម៌ស្ងប់ទេ យើងរំលឹកឲ្យទោសមោហៈអីនិងឲ្យអស់ទៅ វាចប់ហើយ សុខសានហើយ យើងកុំឲ្យកើតមាន

កល្យានៈ លោកតាកន្លែងចេតីយនេះដាក់ធាតុអ្នកស្រុកធម្មតា ឬក៏មានធាតុអ្នកដែលកើតសម័យខ្មែរក្រហម?

ជួនៈ មានតែចាស់ៗ ខ្មែរក្រហមមាននៅនោះ រាប់ពាន់នាក់អ្នកគ្រូ មិនតិចទេ ប៉ុនៗផ្លែដូង និង

កល្យានៈ នៅឃុំណាលោកតា?

ជួនៈ នៅក្រាំងតាចាន់ណ៎ា

កល្យានៈ ចុះនៅម្តុំជិតៗយើងនេះមានទេ?

ជួនៈ ម្តុំជិតៗគ្នានេះអត់ទេ ក្រាំងតាចាន់និងខ្ញុំទៅញឹកណាស់ណ៎ា

កល្យានៈ លោកតាទៅឃើញម៉ិចខ្លះ?

ជួនៈ ឃើញក្បាលគេគរទុកម្តុំនិង កាលពីលោកតាមិនទាន់ទៅធ្វើរោងនៅនិងណា

កល្យានៈ ប៉ុន្តែចង់សួរថា កាលពីជំនាន់អាពតលោកតាធ្លាប់ទៅនិងទេ?

ជួនៈ អត់ដែលសោះ គេអត់ដែលឲ្យទៅនិងទេ យើងមិនមែនមូលដ្ឋានម៉ិចនិងបានទៅ អត់ដែលឲ្យស្គាល់ដីគេទេ

កល្យានៈ លោកតាដែលទៅចូលរួមបុណ្យ ២០ ឧសភានៅកន្លែងណាទេ?

ជួនៈ បុណ្យប៉ុលពតហេះ?

កល្យានៈ បុណ្យចងកំហឹង ២០ ឧសភានិង

ជួនៈ អានិងនៅវត្តគេធ្វើមួយឃុំលាយបូរគេធ្វើនៅវត្ត

កល្យានៈ អញ្ចឹងលោកតាធ្លាប់ចូលរួមដែរ?

ជួនៈ បាទ ចូលរួមដែរ

កល្យានៈ ហើយកាលនិងលោកតាធ្វើអាចារ្យហើយឬនៅ?

ជួនៈ កាលនិងនៅទេខ្ញុំ

កល្យានៈ លោកតាយល់ឃើញថាម៉ិចដែរ ចំពោះវិធីនិង?

ជួនៈ យី មិនដឹងយល់ឃើញថាម៉ិចទេ អ្នកគ្រូ ខ្ញុំមិនសូវប្រសប់និយាយ

កល្យានៈ លោកតា ខ្ញុំចង់សួរបកទៅជំនាន់អាពតតិចណាលោកតា ជំនាន់និងថាលោកតាដែលតែពិសារបបរ អត់ដែលបានពិសារបាយអីអញ្ចឹង ចុះអ្នកផ្សេងទៀតគេអញ្ចឹងដែរលោកតា?

ជួនៈ បាទ ដូចតែគ្នានិង រាំទូទាំងភូមិហើយនិង

សាវីណាៈ ចុះលោកតាដែលឈឺទេកាលពីជំនាន់ប៉ុលពតនិង?

ជួនៈ ខ្ញុំសុំលើកតិចចុះ កាលពីជំនាន់ប៉ុលពតនិងខ្ញុំអត់សូវឈឺទេ ខ្ញុំឃើញថាស្រួលតែម្តង បំរើការងារអគ្គការនិងដូចថាស្រួល អត់សូវឈឺអីទេ

សាវីណាៈ ចុះអត់ដែលឈឺទេ ចុះមានដែលឃើញអ្នកផ្សេងឈឺទេលោកតា?

ជួនៈ លោកតាដែលឃើញឈឺចាស់ៗ មានពេទ្យមានអីគេ ពេទ្យនិងណា

សាវីណាៈ ចុះពេលឈឺទៅពេទ្យអីអញ្ចឹង គេមានយកចិត្តទុកដាក់លើយើង មានខ្វះខាតថ្នាំអីទេ

ជួនៈ បើតាមខ្ញុំពិនិត្យទៅ គេយកចិត្តទុកដាក់ដែរ

សាវីណាៈ មានថ្នាំ មានអីគ្រប់គ្រាន់ទេលោកតា?

ជួនៈ ថ្នាំនិងបើតាមខ្ញុំពិនិត្យមើល អត់មានថ្នាំអីល្អទេ មានតែអាថ្នាំខ្មៅៗនិង ហើយបើយើងឥឡូវនេះគេថាថ្នាំបំបាត់ឈឺពោះ ថ្នាំអាម៉ុកអីនោះ មានសំបុរអញ្ចឹង ធ្វើប្រឌិតខ្លួនឯងនិងតែវាអត់ពូកែដូចថ្នាំយើងឥឡូវនេះទេ

សាវីណាៈ ចុះលោកតាធ្លាប់លឺនៅកន្លែងផ្សេងឈឺហើយថ្នាំអត់គ្រប់គ្រាន់អីដែរលោកតា កាលពីជំនាន់និង?

ជួនៈ ខ្ញុំមិនបានដឹងដែរអ្នកគ្រូ ចំពោះខ្ញុំតែម្តង កូនខ្ញុំខូចជើងនិង កើតពិស អញ្ចឹងពេទ្យគេអត់មានឲ្យថ្នាំយើងហូបទេ គេឲ្យតែឬសឈើអី យើងរើសខ្លួនឯង

សាវីណាៈ ចុះលោកតាទៅកងអីអញ្ចឹងមានផ្ទះនៅគ្រប់គ្រាន់ទេលោកតា?

ជួនៈ យី! បានផ្ទះឯណាអ្នកគ្រូ ថែបណា ដែលទាន់ទេ?

សាវីណាៈ អត់ទេលោកតា

ជួនៈ ស្លឹកពីរកណ្តុបណាអ្នកគ្រូ ដេកគ្នាអញ្ចឹងមក ស្លឹកពីរកណ្តុបអញ្ចឹងមក ស្លឹកពីរកណ្តុបមកល្មមតែផុតជើងយើងនិងណា៎ ទៅដល់បោះបង្គោល ក្រឡោង២អញ្ចឹងមកណា

សាវីណាៈ អ្នកផ្សេងអញ្ចឹងដែរលោកតា?

ជួនៈ ដូចតែគ្នា ទាំងអស់

សាវីណាៈ ចុះលោកតាធ្លាប់គេចាប់ដាក់ឃុំឃាំង ឬដាក់គុកកន្លែងណាអត់?

ជួនៈ អត់សោះ

សាវីណាៈ តែមានដែលឃើញគេជាប់គុកអីទេលោកតា ?

ជួនៈ ជាប់គុកខ្ញុំអត់ដែលឃើញដែរ អត់ដែលឃើញទេ

សាវីណាៈ តែមានដែលលឺទេលោកតា?

ជួនៈ លឺតែគេថា អង្គការចាប់អ្នកនេះទៅហើយនោះ ឃើញចង់អីអញ្ចឹងដែរ

សាវីណាៈ លោកតាធ្លាប់ឃើញគេរបួសអីធ្ងន់ទេលោកតា?

ជួនៈ អត់ដែលឃើញទេ

សាវីណាៈ ធ្លាប់លឺថាគេត្រូវរបួសអីទេលោកតា គេត្រូវគ្រាប់ទេលោកតា?

ជួនៈ អត់ដែលឃើញដែរ

សាវីណាៈ ចុះជំនាន់ប៉ុលពតនិងលោកតាមានដែលពេលគេបាញ់គ្នា លោកតានៅកន្លែងគេបាញ់គ្នានិងទេ?

ជួនៈ ដែល ខ្ញុំនៅទាហានខ្ញុំបាញ់ដែរនិង

សាវីណាៈ តែកាលពីជំនាន់ប៉ុលពតណា៎?

ជួនៈ ជំនាន់ប៉ុលពតអត់ដែលឃើញ។ ខ្ញុំឃើញអញ្ចេះមួយដែរ គេវ៉ៃណា៎ យុវជនទៅបោចស្មៅខែប្រាំង មិនដឹងមានការអីទេ គេចងយកមក ខ្ញុំនៅកងជាងសំណង់និងណា៎ អញ្ចឹងវ៉ៃចោលលើថ្នល់នេះ៣នាក់ សម្លាប់ចោលតែម្តង យុវជនពាក់អាវស គ្នាពាក់មកខោជើងត្រង់ មិនដឹងជាកូននរណាទេ នៅស្រុកណាខេត្តណាទេ វ៉ៃបែកក្បាលខ្ទេច កប់នៅ និងកប់មួយរណ្តៅ

សាវីណាៈ លោកតាធ្លាប់ដែលឃើញគេវ៉ៃផ្ទាល់ដែរ?

ជួនៈ វ៉ៃផ្ទាល់ដែរខែភ្ជុំ ថ្ងៃពេញបូរណ៍ ខ្ញុំចេញឈឺពោះយប់ឃើញនៅលើថ្នល់ជាតិ

សាវីណាៈ ចុះក្រៅពីលោកតាឃើញផ្ទាល់អញ្ចឹង លោកតាមានដែលធ្លាប់លឺគេវ៉ៃមនុស្សនៅកន្លែងណាផ្សេងទៀតទេ?

ជួនៈ អត់ ឃើញតែឃើញថ្ងៃមួយគ្នាខ្ញុំ៣នាក់ មកឡើងត្នោតណា នៅកងខ្ញុំគេធ្វើត្នោត ដល់ពេលឡើងត្នោត ម្នាក់គេឡើងទៅ ខ្ញុំនៅអង្គុយក្រោម អញ្ចឹងព្រៃតាមថ្នល់អញ្ចឹងមួយដូរអញ្ចឹងទៅណា៎ អញ្ចឹងគេសួរចម្លើយបណ្តើរមក គេមានគល់ឬស្សីមួយ កាំភ្លើង២ ដើមបណ្តើរយុវជននិងមកណា ៣នាក់និងមកពីស្រែប្រាំងណា៎ ហើយឈ្លប២នាក់ មកដល់ភូមិនិង វែងចុះៗ វ៉ៃតែម្តង វ៉ៃដួលអូយៗ ដូស ហើយបាត់ដង្ហើមទៅ

សាវីណាៈ កាលពីជំនាន់និងលោកតាធ្លាប់លឺគេសម្លាប់នៅនេះ នៅនោះអី មានលឺទៀតទេ?

ជួនៈ អត់ទេ ដល់ហើយស្រាប់តែមួយសន្ទុះទៅរកចបកន្លែងជាងខ្ញុំនិង តំណាងកងគាត់ទៅផ្ទះថ្ងៃនិងណា ខ្ញុំហើយនិងចុងភៅរកឲ្យចបកាប់បាន២។ ដល់បានពីរមកកាប់ដី កាប់ដីវែងឈ្លបទៅហៅមក មកគ្នា៤-៥នាក់ ខ្ញុំក៏មកដែរ ហើយកាប់បានតែត្រឹមនេះ លើជង្គង់បន្តិចទំលាក់ទាំង៣អូសតែម្តង អ្នកគ្រូអើយ ដូចឆ្កែ សរៗ ចាប់អូសដៃមក អញ្ចឹងជើង

វាធាក់ធ្លាក់គន្ទក់ទៅ ជើងវារុញធ្លាក់គន្ទក់ទៅ រុញនិងជើងណា៎ ហើយអាមួយទៀតចាប់ជើងទាញមកដល់ត្រឹមនិង ជើងវាធាក់ចូលគន្ទក់និង ដុយគ្នានិង ខ្វះក្បាលទៅកើត ខ្វះក្បាលមកលិច ហើយលប់ដីមក គេដាក់បន្ទាស្អិតពីលើនិងពីរមែក ហើយលប់ទៅ ឲ្យពួកខ្ញុំនិងជួយលប់ ឈាមកាត់ថ្លុក បៀតៗរណ្តៅនិងណា ថ្ងៃត្រង់ហើយនៅតែក្រហមឈាមនៅកកនិង ក្បាលបែក រីតែក្បាលទេ

សាវីណាៈ ចុះក្រៅពីលោកតាឃើញគេសម្លាប់អញ្ចឹង លោកតាធ្លាប់លឺពីរឿងបងប្អូនឯងសម្លាប់បងប្អូនឯង កូនសម្លាប់ឪពុកអីទេ កាលពីសម័យនិង?

ជួនៈ ដូចជាគ្មានទេអ្នកគ្រូ

សាវីណាៈ ចុះលោកតាដែល ពេលដែលគេធ្វើប្រវត្តិរូបអីហើយ លោកតាដែលគេហៅទៅអប់រំអីអញ្ចឹងណា៎ ចុះអ្នកផ្សេងមានដែលគេយកទៅអប់រំទៅណែនាំអីអញ្ចឹងដែរទេ?

ជួនៈ ពួក ធ្វើទាហានប៉ុន្មាននិង គេយកទៅអប់រំដែរនិងណាអូន

សាវីណាៈ គេយកទៅទាំងអស់?

ជួនៈ បាទ យកទៅទាំងអស់អ្នកដែលមានប្រវត្តិរូ ធ្វើទាហាននិងណា៎

សាវីណាៈ ចុះកន្លែងផ្សេងទៀតគេយកទៅអប់រំអីដែរលោកតា?

ជួនៈ កន្លែងផ្សេងទៀតគេយកទៅអប់រំឲ្យយើងបំពាក់ជីហ៊ ទទួលការខុសត្រូវជាមួយអង្គការនិងណា៎

សាវីណាៈ ជំនាន់ប៉ុលពតនិងលោកតាមានដែលលឺពីការប្រយុទ្ធគ្នាទេលោកតា?

ជួនៈ ខ្ញុំលឺសូរដែរកាលពីខ្ញុំបែកមកហើយនិងណា៎ ចូលមកនៅក្នុងស្រុកហើយនិង លឺសូរបាញ់ជាមួយយួនអីនិងណា៎ អស់និងអីសុទ្ធតែគ្រាប់ផ្លោងហើយអ្នកគ្រូ ដេញពីតាកែវមកណា៎

សាវីណាៈ លោកតាធ្លាប់លឺរឿងគេរំលោភនារីអីទេ កាលពីជំនាន់និង?

ជួនៈ ជំនាន់ប៉ុលពតនិងអត់ទេ ភូមិខ្ញុំដូចជាគ្មានទេ

សាវីណាៈ ចុះលោកធ្លាប់លឺគេនិយាយពី ដូចថានរណាមួយគេចាប់ដាក់កន្លែងណាមួយតែឯងទេ អត់ឲ្យជួបអ្នកដទៃទេ?

ជួនៈ កាលពីជំនាន់និងមានប្អូនជីដូនមួយខ្ញុំមួយ ឈ្មោះសន វាកាលនិងកាលនិងខ្មែរក្រហមចូលមកនៅកាន់កាប់ដីអស់និងហើយណា៎ គ្នាឆ្លុះកង្កែប ដល់គេចាប់បានគេចាប់ដាក់ទៅនៅក្រាំងតាចាន់ដែលអ្នកគ្រូនិយាយម៉ិញនិង យកទៅដាក់គុកនៅនិង មួយឆ្នាំ គេអត់សម្លាប់ទេ តែគេយកទៅរៀនសូត្រនៅនិងណា៎ គេបង្អត់បាយបង្អត់ទឹកគ្នានិង មួយឆ្នាំកន្លងមកទើបគេមកសួរប្រវត្តិរូប និងខ្ញុំលឺណា៎ ខ្ញុំនៅតាកែវនិងអត់ដឹងទេណា៎ គេសួរប្រ

វគ្គរូបអីចេះអីចុះហើយគេឲ្យប្រពន្ធនិងទៅទទួលខុសត្រូវណា៎ បានគេលែងនិងមករកស៊ីជាមួយប្រពន្ធវាសព្វថ្ងៃនិងមកហេះ

សាវីណាៈ ជំនាន់ណាកាលនិង?

ជួនៈ ជំនាន់ខ្មែរក្រហម

សាវីណាៈ អញ្ជឹងគាត់នៅរស់ទេសព្វថ្ងៃ?

ជួនៈ នៅរស់

សាវីណាៈ គាត់នៅភូមិអី?

ជួនៈ ភូមិនិងដែរនិង តែផ្ទះជិតនេះ ចាប់វាវាកំពុងតែឆ្នុះកន្ត្រែប ខ្មែរក្រហមគេចាប់ទៅណា៎ ចាប់យកទៅមួយឆ្នាំទើបគេឲ្យប្រពន្ធចូលទៅជួប ហើយឲ្យប្រពន្ធធានាទទួលខុសត្រូវ បានគេលែងឲ្យមកវិញណា

សាវីណាៈ ចាប់យកទៅក្រាំងតាចាន់និង?

ជួនៈ និងហើយ យកទៅក្រាំងតាចាន់និង

សាវីណាៈ គាត់ឈ្មោះអី?

ជួនៈ អោម សន ចាប់យកទៅនៅនិង

សាវីណាៈ គាត់នៅភូមិនិងដែរ?

ជួនៈ បាទភូមិនិងដែរ

សាវីណាៈ ផ្ទះគាត់នៅឯណា?

ជួនៈ នៅខាងជើងនេះ

សាវីណាៈ ចុះលោកតាដែលជួបរឿងប៉ិះនិងស្លាប់ខ្លួនទេលោកតា?

ជួនៈ អត់ដែលជួបទេ

សាវីណាៈ ចុះដែលឃើញនរណាជួបហេតុការណ៍ប៉ិះនិងស្លាប់ខ្លួនហើយអត់អីវិញទេ?

ជួនៈ អូ! និងមានក្នុងភូមិនិងមួយ ខ្ញុំលើកឧទាហរណ៍ឲ្យអ្នកគ្រូស្តាប់តិចទៅណា គាត់ទើបនិនិយាយប្រាប់ខ្ញុំក្រោយនេះទេ ។ ពូគាត់ដែលបំរុងនិងស្លាប់និងឈ្មោះម៉ន អញ្ជឹងក្នុងភូមិនិងមានម៉នដល់ទៅ៣ ដល់តែពេលស្លាប់ទៅគេឲ្យយកម៉ននេះ ឧទាហរណ៍ថា មួងម៉ង អញ្ជឹងទៅណា៎ ហើយនោះឈ្មោះ ម៉នអីទៅ ហើយដល់ពេលមកយក យកឲ្យច្រលំទៅ ណា៎ ឈ្មោះ ម៉នដូចគ្នាតែត្រកូនខុសគ្នា អញ្ជឹងគេយកទៅហើយបាត់ទៅ ហើយមួងម៉ន យកឈ្មោះច្រឡំ

សាវីណាៈ លោកតាអត់ដែលឃើញទេហេះពេលដែលប៉ិះនិងស្លាប់អីអញ្ជឹងណា៎?

ជួនៈ អត់ដែលឃើញទេ ធ្លាប់តែលឺគេនិយាយ

សាវីណាៈ ចុះជំនាន់និងលោកតាអត់បានរស់នៅជាមួយប្រពន្ធ ម្ដាយអីទេ លោកគេឲ្យទៅកងអី អញ្ចឹង គេបំបែកអញ្ចឹងគេបន្ទុំលោកតាដែរអត់ទេ?

ជួនៈ បន្ទុំឲ្យធ្វើការនិង ម៉ោង៤ជិតភ្លឺនិងឡើងធ្វើហើយ អញ្ចឹងយើងធ្វើរហូតទល់ម៉ោង១១ អញ្ចឹងចុងភៅគេមានណាអ្នកគ្រូ ដល់ពេលខែប្រាំងអញ្ចឹង យើងធ្វើការទៅ មានចុងភៅ អីដាំបាយទៅ បាយនិងបាយបេះៗទៅណា ស្លត្រោក ស្លត្រកួន ស្លព្រលិតអីនិងណា តែមិនមែនច្រើនមុខទេ តែមួយមុខទេណាអ្នកគ្រូ អញ្ចឹងច្រើនស្ពន់ដីរស្លឹកធំៗនិង

សាវីណាៈ តែគេអត់មានឲ្យជួបបងប្អូន សាច់ញាត្តិអីទេ?

ជួនៈ បាទ គេអត់មានឲ្យទៅទាក់ទងរកបងប្អូនអីទេ អត់ទេ បើជួបបងប្អូនបងប្អូនយើង ជួបតែ នៅអ្នកដែលធ្វើការជាមួយគ្នានិង

សាវីណាៈ ចុះធ្លាប់លឺនៅកន្លែងផ្សេងគេអត់ឲ្យជួបបងប្អូនអញ្ចឹងដែរទេ នៅតាមភូមិ សហករណ៍ ផ្សេង?

ជួនៈ ដូចគ្នាទាំងអស់ សហករណ៍ណាក៏ដូចសហករណ៍ណាដែរ

សាវីណាៈ លោកតាមានមានសាច់ញាត្តិដែលស្លាប់ ហើយលោកតាយល់ថាខុសពីធម្មតាទេលោក តា?

ជួនៈ ស្លាប់យ៉ាងម៉ិច?

សាវីណាៈ ស្លាប់ដែលលោកតាយល់ថាស្លាប់ខុសពីគេពីឯងអញ្ចឹងណា៎?

ជួនៈ អត់ទេ

សាវីណាៈ ចុះមានដែលឃើញនរណាមួយមានបងប្អូនស្លាប់ខុសប្លែកទេ?

ជួនៈ អត់

សាវីណាៈ តាដែលវង្វែងទៅភូមិណាមួយដែលលោកតាអត់ដែលស្គាល់ទេលោកតា?

ជួនៈ អត់ព្រោះកាលពីជំនាន់និងគេមិនដែលឲ្យទៅណាដងអ្នកគ្រូ ការងារអីយើងទទួលការងារ អី យើងធ្វើការងារនិង ម៉ោង១១យើងឡើងហូបបាយទៅ ហើយម៉ោង១យើងចាប់ធ្វើ ការវិញទៅ ហើយម៉ោង៥ឈប់ទៅ

សាវីណាៈ ចុះលោកតាមានដែលឃើញនរណាវង្វែងទេលោកតា?

ជួនៈ ដែលតែអញ្ចេះ ប្ដីធ្វើទាហាន អានិងនៅថ្នល់ទទឹងណោះ ដល់ពេលវាអត់ស៊ីពេក រត់មក រកបងប្អូននេះហូប ដល់មកដល់នេះ សហករណ៍ខ្ញុំគេឲ្យហូបបាយបេះៗនិងណា៎ ហើយ នៅនេះបបរចែកមួយវែកម្នាក់និង ហើយប្ដីគ្នាធ្វើទាហានណា៎ ហើយកាលពីដើមគេមាន

ណា៎ ដល់ពេលស៊ីមិនឆ្អែតរត់មកនេះ ដល់រត់មកនេះឈ្លបគេមកតាម ហើយគាត់រត់ពួន ដល់រត់ពួនឈ្លបរកអត់ឃើញ ទៅចងករងាប់ទៅ ហើយសល់កូនមួយ ដល់ប្អូនគេយកទៅចិញ្ចឹម ឥឡូវបានប្តីធ្វើគ្រូហេះ

សាវីណា: លោកតាឃើញផ្ទាល់ឬគ្រាន់តែលឺគេនិយាយទេ?

ជួនៈ ខ្ញុំឃើញផ្ទាល់ ចង់ដើមអញ្ចឹយ

សាវីណា: តែគាត់ដើរវង្វេងហេះ?

ជួនៈ គាត់អត់វង្វេងទេ គាត់រត់មករកបងប្អូនម៉ង ក្រែងលោខាងនេះគេមានហូបច្រើនជាងខាងនោះណា៎ ចង់ជូរសហករណ៍ ហើយនោះគេមានធ្វើលិខិតឲ្យចេញមកឯណា លួចរត់មកនិង ហើយគាត់និងបើតាមការពិតទៅ ខ្ញុំលឺគេនិយាយ គាត់ដូចជាសរសៃប្រសាទដងណា៎ តាំងពីគេសម្លាប់ប្តីទៅ ហើយប្តីគាត់ពីដើមមានឡានតាក់ស៊ីអីរត់ត្រឹមត្រូវណា៎ ហើយដល់ពេលចូលមកសង្គមនិង គេសម្លាប់ប្តីទៅ នៅសល់គាត់និង នៅកូនមួយ ហើយគាត់និងពរកូនមករត់មកនៅសហករណ៍ខ្ញុំនេះ គេមានបាយ បបរដែរ តែបបរប៉េះៗណា

សាវីណា: លោកតាធ្លាប់លឺគេវង្វេងអីដែរកាលពីជំនាន់ប៉ុលពតនិង?

ជួនៈ ដូចជាគ្មានទេ

សាវីណា: លោកតាថាធ្លាប់ឃើញគេវៃធ្វើបាបមនុស្សគេដែរហេះលោកតា?

ជួនៈ ខ្ញុំឃើញគេវៃដូចខ្ញុំប្រាប់អ្នកគ្រូម៉ិញនិង

សាវីណា: មិនមែនសម្លាប់ទេ វៃធ្វើបាបណា៎

ជួនៈ វៃក្នុងកងហេះ?

សាវីណា: ចា៎

ជួនៈ អត់ដែលទេ

សាវីណា: ធ្លាប់លឺថាគេធ្វើទារុណកម្ម គេវាយធ្វើបាបអីដែរអ្នកគ្រូ?

ជួនៈ អត់ដែលឃើញទេអានិង វាយដំអីធ្វើការនិងណា៎ ប៉ុលពតតែខុសគេមិនវាយដំយើងនេះ ទេ គេយកទៅហើយ តែខុសគេយកទៅហើយ មិនដែលឃើញមកវិញទេ

សាវីណា: ចុះក្រៅពីលោកតារៀបរាប់ប្រាប់ខ្ញុំនិង លោកតាមមានដែលជួបរឿងរ៉ាវផ្សេងដែលលោកតាគិតថារន្ធត់ទេ ឬមួយធ្វើឲ្យលោកតារងគ្រោះថ្នាក់អីណា៎?

ជួនៈ បាទ អត់ដែលជួបទេ

សាវីណា: អត់ដែលជួប អត់ដែលលឺទេហេះ?

ជួនៈ បាទ អត់

សាវីណាៈ ចុះកាលពីជំនាន់អាពតនិង លោកតាជួបហេតុការណ៍ច្រើនណាស់ លោកតាយល់ថាហេតុការណ៍ណាមួយដែលឈឺចាប់ជាងគេបំផុតលោកតា?

ជួនៈ ឈឺចាប់ជាងគេពេលគេសម្លាប់ឪពុកនិងម៉ែង ខ្ញុំទៅតស៊ូធ្វើទាហាន

សាវីណាៈ កាលនិងខាងណាអ្នកសម្លាប់លោកតា?

ជួនៈ ប៉ុល ពត ខ្មែរក្រហមនិង

សាវីណាៈ លោកតាដឹងដែរ?

ជួនៈ ដឹង អ្នកដែលសម្លាប់និងក៏ខ្ញុំដឹងដែរ

សាវីណាៈ ភូមិនិងម៉ែងហេះ?

ជួនៈ អត់នៅភូមិនិងទេ តែគេធ្វើឈ្លបណា៎

សាវីណាៈ អត់ទេគេសម្លាប់ឪពុកនិងណា៎?

ជួនៈ សម្លាប់ឪពុកនិងគេធ្វើឈ្លបណា៎ តែដឹងថាអ្នកនិងឥឡូវវាក្រលេចមល្លាមរកអីស៊ីមិនបានទេ តែឥឡូវអ្នកដែលសម្លាប់និងស្លាប់មួយហើយ គេបាញ់និងតែម្ដង គេលបបាញ់ណា គេស្អប់ណាស់អ្នកគ្រូ

សាវីណាៈ ចុះគេបាញ់ឪពុកលោកតានៅឯណា?

ជួនៈ នៅនិងភូមិខាងត្បូងនេះ

សាវីណាៈ នៅកន្លែង...?

ជួនៈ នៅនិងផ្ទះរបស់គាត់តែម្ដង

សាវីណាៈ កាលនិងឆ្នាំ?

ជួនៈ ៧១

សាវីណាៈ លោកតាដែលគេវាយត្រូវក្បាលអីទេតាំងពីតូចរហូតដល់ធំ?

ជួនៈ អត់ទេ អត់មាននរណាដែលវ៉ៃ ដេទេ

សាវីណាៈ ចុះដែលលង់ទឹកទេលោកតា?

ជួនៈ អត់ទេ

សាវីណាៈ ចុះឥឡូវមានដែលចេះតែថប់ៗដង្ហើមទេ?

ជួនៈ បាទ ដល់ចាស់ទៅវាដូចជារៀងថប់ដែរនិង

សាវីណាៈ ប៉ុន្មានឆ្នាំហើយលោកតា?

ជូនៈ ចាប់ពីឆ្នាំទៅម៉ិញនិងមកដើរហត់ ចូល៦៥និងចេះតែប្រែកៗតិចៗដែរនិងណាអ្នកគ្រូ តែការផាររក្ខរាស់អីនៅជួយកូនដែរនិងណា៎

សាវីណាៈ លោកតាដែលធ្លាប់សន្លប់ទេលោកតា?

ជូនៈ យី! ខ្ញុំឆ្នាំមុននិងអស់រយៈពេលមួយម៉ោងដាងណោះ ខ្យល់ណា៎ ខ្យល់ឆក់អត់ដឹងទេ ម៉ោង៣ជិតភ្លឺណា៎ អត់ដឹងខ្លួនប្រហែលជាមួយម៉ោងពីរម៉ោងណោះ កូនចាប់ច្របាច់អីទៅដឹងខ្លួនទៅណាអ្នកគ្រូ

សាវីណាៈ តែម្តងនិងទេ?

ជូនៈ តែម្តងនិងទេតាំងពីក្មេងៗមក ខ្ញុំមិនដែលទេ អត់ទេ

សាវីណាៈ ចុះលោកតារហូតមកដល់ឥឡូវនិង លោកតាមានដែលគិតទៅដល់កាលពីសម័យប៉ុលពតនិងទេលោកតា?

ជូនៈ យី! នៅឈឺចាប់រាល់តែថ្ងៃនិង

សាវីណាៈ លោកតាគិតញឹកញាប់អត់?

ជូនៈ គិតញឹកញាប់ដែរនិង ដេកបន់ស្រន់ថាកុំឲ្យកើតមានឡើងមកទៀតនិងណា៎ ឲ្យវាបានសុខប្រហែលជារាល់ថ្ងៃនិង សប្បាយចិត្តណាស់ អ្នកគ្រូអើយ............

Cassette 2
Side B

ជូនៈ .....វានឹកឃើញរឿងនិងឡើងដូចជាថ្មីដែរនិងណាអ្នកគ្រូ វានៅមានកំហឹងឈឺចាប់និង ណា៎

សាវីណាៈ នឹកឃើញថ្មីនិង ខ្លាំង តិច ឬល្មមលោកតា?

ជូនៈ ល្មមដែរទេ

សាវីណាៈ លោកតាពេលយប់ដែលយល់សប្តិអីអាក្រក់ទេ យល់សប្តិឃើញគេដេញបាញ់អីកាលពីជំនាន់អាពតណា៎?

ជូនៈ ដែលដែរអ្នកគ្រូ

សាវីណាៈ ឥឡូវៗនិងណា៎?

ជូនៈ បាទ ឥឡូវៗនិងដែរនិង យល់សប្តិឃើញគេដេញបាញ់អីអញ្ចឹងដែរណា៎ យល់សប្តិភ័យណា៎

សាវីណាៈ យល់សប្តិភ័យនិងញឹកញាប់ឬម្តងម្កាលទេ?

ជួនៈ អត់ទេ អត់ដែលញឹកញាប់ទេ

សាវីណាៈ រាល់ថ្ងៃលោកតាមានដែលមិនចង់រវីរវល់ មិនចង់ជួបជាមួយអ្នកផ្សេងអីទេលោកតា? ដូចថាចង់គេចអីទេ?

ជួនៈ ទេខ្ញុំមិនចង់គេចទេ ពេលមានភ្ញៀវអី ផ្ទះខ្ញុំមិនដែលដាច់ទេរឿងភ្ញៀវ លោកប្រសក់អី ណា អ្នកមុខអ្នកការអី គាត់មក អត់ដែលដាច់ទេ ជានិច្ចជាកាល

សាវីណាៈ លោកតាឆាប់ភ្ញាក់ផ្អើល ឆាប់ភ័យខ្លាចអីទេ ពេលមានរឿងអី?

ជួនៈ ខ្ញុំវាគ្មានរឿងអីគួរឲ្យភ័យខ្លាចទេ

សាវីណាៈ ឥឡូវៗណា?

ជួនៈ បើមកឥឡូវអត់ទេអ្នកគ្រូ

សាវីណាៈ ចុះពេលលោកតាគិតលើរឿងអីនិង លោកតាប្រមូលអារម្មណ៍គិតលើរឿងនិងបានល្អ ទេ?

ជួនៈ គិតបានល្អដែរ បើគិតមិនចេញក៏ខ្ញុំមិនធ្វើសាលាវិទ្យាល័យនិងកើតដែរ

សាវីណាៈ លោកតារាល់យប់សំរានលក់ស្រួលទេ?

ជួនៈ បាទ ស្រួល

សាវីណាៈ ចុះពេលមានរឿងអីបន្តិចបន្តួចអី លោកតាឆាប់ខឹង ឬមានកំហឹងផ្ទុះចេញមកទេ?

ជួនៈ អត់អីទេអ្នកគ្រូ ខ្ញុំតមបានអារឿងខឹងនិងណា៎ ខ្ញុំតមបានព្រោះខ្ញុំកាន់ចិត្តថាមិនខឹងណា៎

សាវីណាៈ លោកតាពេលលោកតាគិតរឿងអីមួយពេលដែលធ្វើឲ្យលោកតានឹកឃើញដល់សម័យ ប៉ុលពតណា៎ លោកតាចង់ជៀសវាងអត់ចង់ជួបរឿងនិងទេលោកតា?

ជួនៈ បាទ អត់ចង់ជួបទេរឿងនិង

សាវីណាៈ ឧទាហរណ៍ថាលោកថាធ្លាប់ឃើញគេបណ្តើរមនុស្សយកទៅសម្លាប់នោះ ហើយស្រាប់តែ មកដល់សម័យនេះ លោកតាឃើញរឿងអញ្ចឹងៗ លោកតាគេចតែម្តងណា៎ លោកតា មានអញ្ចឹងទេរាល់ថ្ងៃ?

ជួនៈ អារឿងបណ្តើរនិងខ្ញុំមិនដែលឃើញទេឥឡូវនេះ តែកាលពីប៉ុលពតខ្ញុំឃើញដែរ ចង់ សេកហើយវ៉ៃនិងស្នូកកាំភ្លើង ក្នុងកងជាមួយខ្ញុំនិង វែកដីដំបូក ហើយកាលនិងខ្ញុំមិន ទាន់ទៅចូលកងជាងសំណង់ទេណា៎ កាប់ដីដំបូកសងខាង ដំបូកធំ ស្រាប់តែមកដល់គេ ហៅឈ្មោះថា ឯងមកនេះ ដល់មកគេយកស្រែអង្រឹងគេ គ្រាន់តែចងហើយគឹប វ៉ៃគ្នា និងស្នូកកាំភ្លើងតែម្តង ភឹងដួលច្រូស អញ្ចឹងចង់អាអើងមួយទៀត ចង់បានបណ្តើរទៅ ទាំងពីរ តាមថ្នល់កើតនិង ទៅវ៉ៃក្នុងភូមិនោះ មិនដឹងជាទៅណាបាត់លុះឥឡូវ

សាវីណា: ចុះលោកតាឃើញគេសម្លាប់អីអញ្ចឹង ហើយលោកតាមើលទូរទស្សន៍ឃើញគេអញ្ចឹង ទៀត លោកតាចង់មើលអត់?

ជួន: អត់ចង់មើលទេ

សាវីណា: លើកតាអត់ចង់មើលអញ្ចឹងញឹកញាប់ប៉ុណ្ណាដែរ?

ជួន: ឃើញគេលេងរឿងឲ្យយើងមើលណា៎ បើលេងរឿងប៉ុលពតនិង ខ្ញុំឃើញដូចជាមិនសូវពេញចិត្តអារឿងមើលនិងទេ អាណិតអាសូរដល់គ្នានិងណាអ្នកគ្រូ ឃើញមាន

សាវីណា: ពេលលោកតានឹកឃើញដល់សម័យអាពតអញ្ចឹង លោកតានឹកឃើញបានល្អិតល្អន់ទេលោកតា?

ជួន: នឹកឃើញបានល្អិតល្អន់ណាស់ខ្ញុំ អត់ឲ្យកើតមានទៀតទេ ព្រោះខ្ញុំឈឺចាប់ខ្លាំងណាស់អ្នក គ្រូ រឿងសង្គមនិងខ្ញុំធ្វើបុណ្យសព្វថ្ងៃនេះសុំជៀសឲ្យរួចទៅ រឿងសង្គមនិងមួយកុំឲ្យកើតឡើងទៀត

សាវីណា: ចុះលោកតាចង់ឈប់គិតពីសម័យពតនិងអត់លោកតា?

ជួន: លែងគិតនឹកនាពីវាហើយ វាទៅបាត់អស់ហើយ យើងលេងនឹកនារឿងឈឺចាប់ហើយ

សាវីណា: ចុះលោកតាអាចបំភ្លេចបានដែរ?

ជួន: អានេះកំហឹងឈឺចាប់មិនបំភ្លេចបានទេអ្នកគ្រូ វានៅតែនឹកខឹងជានិច្ចជាកាលអញ្ចឹងណា៎ អញ្ចឹងបានជាចិត្តខ្ញុំកុំឲ្យកើតឡើងជាពីរលើកនិងណា៎ ឲ្យវាសាបសូន្យតាំងពីនេះតទៅនិង

សាវីណា: តែលោកតាចង់មិនឲ្យនឹកឃើញរឿងនិងអត់ទេ ឬមួយក៏នឹកទៅក៏មិនអីដែរ?

ជួន: បាទ

សាវីណា: លោកតាពេលដែលនឹកឃើញរឿងនិងម្តងៗអញ្ចឹង មានធ្វើទុកអីក្នុងខ្លួនទេលោកតា?

ជួន: អត់មានធ្វើទុកអីទេ តែគ្រាន់តែនឹកឃើញដល់ឪពុកខ្ញុំជាដើមនិងណា៎ នឹកឃើញ ពួកម៉ាក អីធ្លាប់ធ្វើទាហានជាមួយគ្នាគេយកទៅទាំងស្រស់ៗនិងណា៎ ធ្វើទាហានជាមួយខ្ញុំត្រឹម សាជង់សែប សក្តិមួយអីខ្ទេចហើយ អត់មាននៅសល់ទេ តែខ្ញុំគ្មានបានសាជង់សែបអី និងគេទេ កូនទាហានទេណា៎

សាវីណា: លោកតាពេលលោកតាធ្វើការងារ ទៅវត្តអីពិបាកអត់លោកតា?

ជួន: បាទ អត់អីទេ ម៉ូតូខ្ញុំមានជិះ

សាវីណា: ចុះលោកតាមានដែលបន្ទោសខ្លួនឯងថា មកពីខ្លួនអញ្ចឹងៗបានជាជួបរឿងពិបាកអី អញ្ចឹងណា? មកដល់ឥឡូវមានដែលបន្ទោសខ្លួនឯងទេ?

ជួន: អត់ទេ

សាវីណាៈ ហើយមានដែលបន្ទោសខ្លួនឯងថា មិុចក៏មិនស្លាប់ឲ្យហើយទៅ រស់រានមានជីវិតមកធ្វើអីទេ?

ជួនៈ បាទ អត់ទេ មានតែសរសើរជីវិតខ្ញុំថ្ងៃនិងណា៎ ឆ្លងកាត់ប៉ុលពតនិងណា គេបន្តត់បាយប៉ុណ្ណឹងហើយ នៅតែបានរស់ដល់សព្វថ្ងៃ សំណាងណាស់អ្នកគ្រូ

សាវីណាៈ ចុះលោកតាមានដែលគិតអស់សង្ឃឹមទេរាល់ថ្ងៃ?

ជួនៈ អត់អស់សង្ឃឹមទេ បើកាលពីប៉ុលពតអស់សង្ឃឹមដែរនិងណា តែមកឥឡូវអត់អីទេ

សាវីណាៈ ចុះលោកតាមានដែលចេះតែគិតឆ្ងល់ថា ហេតុអីបានជារឿងកាលពីសម័យអាពតនិងកើតមានចំពោះលោកតា មកដល់ឥឡូវមានដែលចេះតែឆ្ងល់ទេ?

ជួនៈ ខ្ញុំនឹកឆ្ងល់ដែរ នឹកឃើញឆ្ងល់ថា ហេតុអីខ្មែរសោះក៏មកសម្លាប់ដែរ ហើយអត់មានដឹងថាបង ប្អូន ហើយញាត្តិសាច់សារលោហិត ហើយចុះបុគ្គលនិងជឿយ៉ាងមិុចបានជាសម្លាប់ខ្មែរគ្នាឯងរង្គាល់អញ្ចឹង ឆ្ងល់អញ្ចឹងឆ្ងល់ធំដែរនិងណា៎

សាវីណាៈ ចុះមានដែលគិតថាខ្មាស់គេទេពេលដែលខ្លួនឯងជួបរឿងអស់និងរហូតមកដល់ឥឡូវ?

ជួនៈ អត់មានខ្មាស់ទេត្រង់និង អត់មានខ្មាស់សោះ

សាវីណាៈ ចុះមានដែលគិតថា មានតែខ្លួនលោកតាម្នាក់ទេដែលឈឺចាប់បែបនិង គេផ្សេងដូចអត់មានឈឺចាប់អីទេ?

ជួនៈ បាទ ប្អូនស្រីៗមានឈឺចាប់មិុចនិងកើត មានតែខ្ញុំនិង ប្រុសនិងត្រូវតែសងឈាមឪពុកទៅណា ហើយគ្នាស្រីបញ្ញាក៏ខ្វី

សាវីណាៈ ចុះក្រៅពីប្អូនស្រីលោកតាគិតថា អ្នកភូមិដទៃទៀតមានដែលគិតថាគេមិនឈឺចាប់ទេ?

ជួនៈ ភូមិដទៃទៀតប្អូនៗសាច់សារលោហិតគាត់និងណា៎ គាត់អាណិតតែគាត់ទេ អាណិតតែឪញោមខ្ញុំនិងព្រោះថាគាត់ស្លូត គាត់ស្លូតណាស់ហើយគាត់អាចារ្យវត្តផង

សាវីណាៈ ចុះលោកតាមានដែលគិតថា អ្នកផ្សេងសុទ្ធតែសត្រូវលោកតាអត់?

ជួនៈ អត់ទេ អត់ដែលមានគិតទេ ព្រោះខ្ញុំមិនដែលធ្វើអីឲ្យខុសផង ហើយខ្ញុំសព្វថ្ងៃ ខ្ញុំអ្នកដឹកនាំគេទៅហើយ ខ្ញុំដឹកនាំថ្វាយបង្គំព្រះរតនត្រៃ ធ្វើបុណ្យធ្វើទានណាអ្នកគ្រូ

សាវីណាៈ លោកតាអ្នកផ្សេងកូនចៅអីអាចពឹងពាក់បានតើអីលោកតា?

ជួនៈ កូនចៅអ្នកផ្សេងផងទាំងពួងនិងខ្ញុំពឹងបាន

សាវីណាៈ លោកតាមានដែលគិតថាអ្នកណាដែលលោកតាទុកចិត្តហើយបែរជាក្បត់ចិត្តលោកតាវិញទេ?

ជួនៈ បែកគ្មានទេខ្ញុំ

សាវីណាៈ ចុះលោកតាពេលលោកតាបានធ្វើអីមួយអញ្ចឹង ស្រាប់តែអ្នកផ្សេងមកប្រាប់លោកតាថាលោកតាបានធ្វើអញ្ចេះៗ តែលោកតានឹកអត់ឃើញសោះមានដែលធ្លាប់អញ្ចឹងទេលោកតា?

ជួនៈ អត់ទេ អត់ដែលទេ

សាវីណាៈ ចុះលោកតាពេលដែលពួកខ្ញុំមករំលឹកពីរឿងអាពតអញ្ចឹងណា ក្នុងអារម្មណ៍លោកតាយ៉ាងម៉ិចដែរ?

ជួនៈ ក្នុងអារម្មណ៍ខ្ញុំសប្បាយរីករាយខ្លាំងណាស់បានអ្នកគ្រូទាំងអស់មកជួយរំលឹករឿងនិងស្រាវជ្រាវរឿងនិងឲ្យបានដឹងគ្រប់គ្នាណា កាលពីដើមឡើយដូចថាគេសម្លាប់ឪពុកខ្ញុំនិងវាគ្មាននរណាដឹងទេ ដឹងតែអ្នកក្នុងភូមិ អញ្ចឹងបានដឹងដល់អ្នកគ្រូមកផ្សព្វផ្សាយអញ្ចឹងខ្ញុំអរណាស់បាទ បានអ្នកគ្រូជួយផ្សព្វផ្សាយប៉ុណ្ណឹងណា ជួយឈឺឆ្អាល់

សាវីណាៈ អញ្ចឹងបើមានគេដឹងរឿងលោកតាអញ្ចឹង លោកតាសប្បាយចិត្តដែរ?

ជួនៈ បាទ សប្បាយចិត្តដែរ បានអ្នកគ្រូដឹងជួយឈឺឆ្អាលអីត្រង់និងណា៎

សាវីណាៈ ចុះបើសិនជាលោកតាមានរឿងតានតឹងផ្លូវចិត្តណា៎ ពេលដែលលោកតាគិតដល់ឪពុកលោកតាស្លាប់អីអញ្ចឹង លោកតាឈឺចាប់អីអញ្ចឹង លោកតាដោះស្រាយផ្លូវចិត្តយ៉ាងម៉ិចដើម្បីឲ្យធូរវិញ?

ជួនៈ ខ្ញុំដូចខ្ញុំជំរាបអ្នកគ្រូអញ្ចឹងថា ខ្ញុំមិនសងឈាមទេអ្នកសម្លាប់និងណា៎ ខ្ញុំទុកឲ្យគាត់និងរកស៊ីធ្វើម៉ិចកម្មរបស់គាត់ ខ្ញុំមិនសងឈាមទេ គិតតែអញ្ចឹងវិញហើយអ្នកគ្រូ

សាវីណាៈ គិតថាកម្មរបស់គាត់ទៅ?

ជួនៈ បាទ កម្មរបស់គាត់ទៅ យើងកុំធ្វើដឹងធ្វើលឺទៅណា នៅតែរាប់គ្នាជាញាតិ ជាមិត្តអីអញ្ចឹងទៅណា៎ ខ្ញុំមិនទៅខឹងទេ

សាវីណាៈ អញ្ចឹងលោកតាអាចរំសាយចិត្តលោកតាបានទេឥឡូវ?

ជួនៈ បាទ ខ្ញុំក្នុងចិត្តនិង ពាក្យយើងយកធម៌ព្រះពុទ្ធដាក់ក្នុងខ្លួនទៅហើយថាយើងទុកជាអាសាបង់ទៅចុះ មិនខឹងអីនិងគេទេ បើយើងខឹងគេទៅសម្លាប់គេក៏យើងគ្មានសិទ្ធទៅសម្លាប់គេវិញ អញ្ចឹងយើងថាទុកជាអាសាបង់ទៅចុះ ធ្វើម៉ិចសន្តមបំពាក់គាត់ សំណាងរបស់គាត់កម្មរបស់គាត់ណាអ្នកគ្រូ

សាវីណាៈ អញ្ចឹងលោកតាគិតថាធម៌?

ជួនៈ បាទ ធម៌ព្រះពុទ្ធណា៎

សាវីណាៈ អញ្ចឹងបើសិនអ្នកបើមានបញ្ហាផ្លូវចិត្ត បើគេនៅតែគុំគួនអត់រំសាយចិត្តអីអញ្ចឹង លោកតាយល់ថាសាសនាយើងអាចជួយបានទេលោកតា?

ជួនៈ សាសនាម៉ិចនិងគាំទ្រមនុស្សអាក្រក់

សាវីណាៈ ប៉ុន្តែអាចជួយរំសាយចិត្តគេបានអត់លោកតា?

ជួនៈ មិនដឹងម៉ិច បើចិត្តរបស់គេ មិនដឹងសាសនាអាចជួយគេកើតឬមិនកើត ខ្ញុំមិនដឹងដែរ តែច្បាប់ព្រះពុទ្ធ បុគ្គលណាអ្នកធ្វើ បុគ្គលនិងទទួលខុស ទទួលហើយ

សាវីណាៈ លោកតាមានដែលនិយាយរឿងរ៉ាវឈឺចាប់ពីសម័យប៉ុលពតនិងឲ្យកូនចៅស្តាប់ទេលោកតា?

ជួនៈ ឈឺចាប់ប៉ុលពតនិងខ្ញុំនិយាយប្រាប់ដែរ និយាយប្រាប់កូនខ្ញុំជារឿយៗអញ្ចឹងមកណា៎ ខ្ញុំ ថាកូនឯងទាំងអស់គ្នានេះមិនទាន់ដឹងពីជំនាន់ប៉ុលពតទេ កូនឯងគ្រាន់តែទាន់ទេ តែវាហូបបាយបបរមួយចាននិងវាឆ្អែតហើយណា៎ ឪនិងម៉ែបាយបបរមួយវែក ហូបម៉ិចនិងឆ្អែត អញ្ចឹងឃើញថាឈឺចាប់ខ្លាំងណាស់ អញ្ចឹងកូនឯងត្រូវ យើងខំណា៎ បានប៉ុណ្ណេះហើយយើងខំបោសំរាម ប្រាប់កូនប្រាប់ចៅដាក់គ្រេ ដាក់ភ្លឺទៅបានវាល្អបានរដ្ឋចែកដីឲ្យម្នាក់២០អានិងណា៎អ្នកគ្រូ អញ្ចឹងយើងខំដាក់ដីហូបលែងខ្វះខាតអីទៅ យើងសប្បាយចិត្តហើយ

សាវីណាៈ អញ្ចឹងលោកតាយល់ថារឿងរ៉ាវកាលពីជំនាន់អាពតនិង គួរតែឲ្យក្មេងៗបានដឹង បានលឺអត់លោកតា?

ជួនៈ ក្មេងអត់ដឹង តែទាល់តែយើងនិយាយប្រាប់វាណាស់ ប្រាប់វាអញ្ចឹងដែរនិងណា៎

សាវីណាៈ អញ្ចឹងយើងត្រូវនិយាយប្រាប់វា?

ជួនៈ បាទ ខ្ញុំវាដឹង

សាវីណាៈ ហេតុអីលោកតា?

ជួនៈ ព្រោះយើងប្រវត្តិវាដូចត់និងមកថាគេឲ្យចៅ កាលនិងម៉ែមីនេះ ឪអានេះអីនៅតូចៗនិងខ្ញុំពរនិង ហើយឥឡូវវាប៉ុណ្ណឹងអស់ហើយនិង កាលនិងខ្ញុំនៅពរគេតើអ្នកគ្រូ

សាវីណាៈ អញ្ចឹងបើសិនជាយករឿងរ៉ាវកាលពីជំនាន់អាពតនិងដាក់ចូលក្នុងកម្មវិធីសិក្សាឲ្យក្មេងរៀនបានអត់?

ជួនៈ មានតើអ្នកគ្រូ គេបង្រៀនដែរតើ

សាវីណាៈ អញ្ចឹងលោកតាយល់ថាវាល្អទេ?

ជួនៈ និងហើយវាល្អ អញ្ចឹងសួរចៅៗនិង កាលពីប៉ុលពតអ្នកគ្រូបាននិយាយយ៉ាងម៉ិចខ្លះថាឲ្យធ្វើយ៉ាងម៉ិចខ្លះកាលពីជំនាន់អ្នកគ្រូនិង មានដែលនិយាយទេ គ្រូៗអស់និងគាត់ធ្លាប់ ហើយអ្នកគ្រូដែលបង្រៀននៅខ្ញុំនិង ថារើសអាចម៍គោដែរនិង ដើររើសអាចគោរអីតាមវាលស្រែនិងណា៎

សាវីណាៈ អូ! អ្នកគ្រូគាត់និយាយរឿងប្រាប់ហេះ?

ជួនៈ បាទ អ្នកគ្រូគាត់និយាយរឿងប្រាប់ថាកូនៗត្រូវខំយកចិត្តទុកដាក់ ។ ខ្ញុំនៅសហគមន៍និងដែរនិង សហគមន៍មាតាបីតាសិស្សត្រង់វិទ្យាល័យ ត្រង់បឋម អញ្ចឹងអ្នកគ្រូនិងគាត់លើកហើយថាឥឡូវកូនៗត្រូវយើងថែសួនច្បារយើង យកអាចម៍គោមក យកមកដាក់សួនច្បារយើងឲ្យល្អ ហើយបើកាលពីអ្នកគ្រូនៅវ័យកុមារដូចកូនៗទាំងអស់និង អ្នកគ្រូដើររើសអាចម៍គោតាមវាលស្រែ យកមកដាក់ក្នុងមួយព្រឹកប៉ុលពតគេកំណត់១០គីឡូ ។ យកមកមានជញ្ជីងគេថ្លឹងត្រឹមត្រូវទៀតទើបគេឲ្យបាយស៊ី និងអ្នកគ្រូគាត់និយាយប្រាប់សិស្សៗនិងណា៎ មួយថ្ងៃ១០០គីឡូណោះ

សាវីណាៈ អញ្ចឹងខ្ញុំអស់មានអីសួរលោកតាហើយ លោកតាមានគំនិតយោបលអីចុងក្រោយទេលោកតា? មានអីចង់ផ្តាំផ្ញើចុងក្រោយទេលោកតា?

ជួនៈ ចុងក្រោយខ្ញុំថា ខ្ញុំសូមថ្លែងអំណរអរគុណដល់លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានមកស្រាវជ្រាវរកមូលហេតុ ជីវប្រវត្តិដូចត់និងណា ហើយក៏ខ្ញុំគ្មានអីនិងរកប្រៀបផ្ទឹមនិងសធាទឹកចិត្តលោកគ្រូអ្នកគ្រូដែលបានមកស្រាវជ្រាវនៅប្រវត្តិរូបសង្ខេបរឿងរ៉ាវឪពុករបស់ខ្ញុំនេះបានទេ មានតែគុណបុណ្យព្រះរតនត្រៃជួយថែរក្សានូវអ្នកគ្រូ លោកគ្រូទាំងអស់គ្នានិងណា៎ បានមកស្រាវជ្រាវនិងក៏សុំឲ្យមានសេចក្តីសុខចំរើន លោកគ្រូអ្នកគ្រូសំរេចព្រះពុទ្ធណាសូមសំរេចដូចក្តីប្រាថ្នា

សាវីណាៈ សាធូបលោកតា

ជួនៈ ខ្ញុំមានតែប៉ុណ្ណឹងទេ

សាវីណាៈ ចា៎ អរគុណលោកតាច្រើន

ជួនៈ បាទ

-ចប់-